## បាឋកថាទិវាជាតិអំណាន

# វាយតម្លៃលទ្ធផលសិក្សា
# របស់សិស្សក្នុងបរិបទ
# នៃការអប់រំក្នុងសតវត្សទី២១

បាឋកថាទិវាជាតិអំណាន

# វាយតម្លៃលទ្ធផលសិក្សា
# របស់សិស្សក្នុងបរិបទ
# នៃការអប់រំក្នុងសតវត្សទី២១

*បណ្ឌិតសភាចារ្យ* **ហង់ជួន ណារ៉ុន**

២០២៣

រចនាទំព័រ និងសម្រួលអត្ថបទដោយគ្រឹះស្ថានបោះពុម្ពផ្សាយ Sipar
© ហង់ជួន ណារ៉ុន
រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅកម្ពុជា

# មាតិកា


**ជំពូកទី១ ក្របខ័ណ្ឌទ្រឹស្តីនៃវង្វាយតម្លៃ** ........................................... ៧

១.១. វង្វាយតម្លៃសិក្សាតាមដំណាក់កាល ..................................៧

១.២. វង្វាយតម្លៃសិក្សាតាមបែបសរុប ....................................... ៨

១.៣. ភាពខុសគ្នារវាងវង្វាយតម្លៃទាំងពីរ .................................. ៩

១.៤. វង្វាយតម្លៃសិក្សាក្នុងកំណែទម្រង់វិស័យអប់រំ ..................១០

១.៥. ភាពជាអ្នកដឹកនាំវង្វាយតម្លៃ ........................................... ១១

**ជំពូកទី២ ក្របខ័ណ្ឌវង្វាយតម្លៃសិក្សា**..........................................១៣

២.១. ក្របខ័ណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ............ ១៣

២.២. ការវាយតម្លៃផ្ទៃក្រៅ និងការវាយតម្លៃផ្ទៃក្នុង.................. ១៥

២.៣. កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស
សម្រាប់ប្រទេសកំពុងអភិវឌ្ឍ (PISA-D) ........................ ២២

២.៤. វង្វាយតម្លៃថ្នាក់តំបន់ SEA-PLM .................................. ៣៣

**ជំពូកទី៣ ក្របខ័ណ្ឌវង្វាយតម្លៃសិក្សា** ..........................................៤៥

៣.១. ប្រព័ន្ធអធិការកិច្ច.......................................................... ៤៥

**ជំពូកទី៤ វង្វាយតម្លៃសិក្សា និងកំណែទម្រង់ ការគ្រប់គ្រង
សាលារៀន**.................................................................... ៤៩

៤.១. ការគ្រប់គ្រងតាមសាលារៀន ........................................... ៤៩

៤.២. អធិការកិច្ចសាលារៀន...................................................៥០

៤.៣. អនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ........................ ៥២

៤.៤. បង្កើតវប្បធម៌ជួយសិស្សតាមរយៈតេស្ត.......................... ៥៤

៤.៥. សកម្មភាពសព្វគ្រប់នៃការធ្វើតេស្តស្តង់ដារវាយតម្លៃ
សមត្ថភាពសិស្ស ...................................................... ៥៦
៤.៦. ការលើកទឹកចិត្តសិស្សរៀនយឺត និងការប្រជុំជាមួយមាតាបិតា
ប្រចាំខែ..........................................................................៥៧

**ជំពូកទី៥ វាយតម្លៃសិក្សា និងកំណែទម្រង់ ការគ្រប់គ្រង
សាលារៀន**........................................................................ ៥៩
៥.១. កំណែទម្រង់វាយតម្លៃសិក្សារបស់សិស្ស...................... ៥៩
៥.២. ការសិក្សាបែបគម្រោង.................................................. ៦៣
៥.៣. វិធីសាស្ត្រវាយតម្លៃសិក្សានៅសាលារៀនជំនាន់ថ្មី (NGS)៦៥
៥.៤. ការវាយតម្លៃក្នុងសិក្សាអក្សរសិល្ប៍................................ ៦៩
៥.៥. ការវាយតម្លៃសិស្ស.........................................................៧០
៥.៦. ការវាយតម្លៃក្នុងការសិក្សាអក្សរសិល្ប៍ ...........................៧០
៥.៧. ការវាយតម្លៃក្នុងការរិះរក ក្នុងការរៀនវិទ្យាសាស្ត្រ .........៧១

# ជំពូកទី១

# ក្របខ័ណ្ឌទ្រឹស្តីនៃវាយតម្លៃ

*និយមន័យ ៖* គឺជាវិធីដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីពិនិត្យមើល ៖

១. តើសិស្សបានរៀនទៅតាមកម្មវិធីសិក្សា ដែលបានកំណត់ឬទេ?

២. តើសិស្សសម្រេចបានវឌ្ឍនភាពក្នុងការសិក្សាយ៉ាងដូចម្តេច? ដល់កម្រិតណា?

៣. តើគ្រូអាចប្រើប្រាស់សម្ភារៈឧបទេស ឬវិធីសាស្ត្របង្រៀនយ៉ាងដូចម្តេច ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស?

វិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមានច្រើន ដូចជាការធ្វើតេស្ត ការប្រឡង ការសង្កេត ការលេងល្បែង ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ ដើម្បីវាយតម្លៃពីកម្រិតចំណេះដឹង និងបំណិនរបស់សិស្ស។

គេតែងតែចែកវាយតម្លៃសិក្សាជាពីររបៀប គឺ ៖

១. វាយតម្លៃសិក្សាតាមដំណាក់កាល (formative assessment) និង

២. វាយតម្លៃសិក្សាតាមបែបសរុប (summative assessment)។

## ១.១. វាយតម្លៃសិក្សាតាមដំណាក់កាល

***វាយតម្លៃសិក្សាតាមដំណាក់កាល*** (formative assessment) គឺជាវិធីដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពរបស់សិស្សនៅក្នុងពេលដែលសិស្សកំពុងរៀន។ ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃសិក្សាតាមដំណាក់កាល គ្រូមានឱកាសក្នុងការកែសម្រួលវិធីសាស្ត្របង្រៀន

សិស្សទៅតាមកម្រិតនៃចំណេះដឹងរបស់សិស្ស។

**វាយតម្លៃសិក្សាតាមដំណាក់កាល** មានទម្រង់ផ្សេងៗ ដូចជាការសួរសំណួរពេលបង្រៀន ការលេងល្បែងសិក្សា ការវាយតម្លៃក្នុងថ្នាក់រៀន ការសង្កេតពីការសិក្សារបស់សិស្ស។

គ្រូបង្រៀនអាចចែកក្រដាសសំណួរស្តីពីមេរៀនដែលបានរៀន ដូចជារូបធាតុផ្សេងៗ ក្នុងការបង្រៀនមុខវិជ្ជាគីមី ឬសួរពីរូបមន្តគណិតវិទ្យា។

គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្រវាយតម្លៃតាមដំណាក់កាលនេះ ដើម្បីរៀបចំការបង្រៀន ទៅតាមចំណេះដឹងរបស់សិស្សម្នាក់ៗ ដោយគ្រូត្រូវពិនិត្យកិច្ចតែងការបង្រៀនឡើងវិញ និងប្រើប្រាស់វិធីសាស្ត្រផ្សេងទៀតដើម្បីបង្រៀនសិស្ស។

នៅក្នុងសៀវភៅ «វិធីសាស្ត្របង្រៀន» លោក ប៉ូ ប៊ុន្ថន ឡុច ចាន់ថន និងឃិន វណ្ណី(២០១៩) បានចែកវិធីសាស្ត្រវាយតម្លៃសិក្សាតាមដំណាក់កាលជា៦ជំហាន៖

១. កំណត់មេរៀនដែលចង់វាយតម្លៃទាក់ទងនឹងគោលបំណង

២. ខ្លឹមសារមេរៀនដែលចង់វាយតម្លៃស្ថិតនៅក្នុងគោលបំណង

៣. រៀបចំផែនការធ្វើតេស្ត ដែលគ្របដណ្តប់គោលបំណង

៤. បង្កើតសំណួរងាយចងចាំ ងាយយល់អនុវត្ត និងវិភាគ

៥. ត្រួតពិនិត្យមើលឧបករណ៍វាស់វែងដែលបានបង្កើត

៦. មើលលទ្ធផល និងព្យាយាមមើលកំហុសក្នុងការអនុវត្ត

## ១.២. វាយតម្លៃសិក្សាតាមបែបសរុប

វាយតម្លៃសិក្សាតាមបែបសរុប (summative assessment) គឺជាវិធីដែលគ្រូបង្រៀនប្រើប្រាស់ក្រោយពេលបង្រៀន ដើម្បីពិនិត្យមើល៖

១. តើសិស្សរៀនចេះបានចំនួនប៉ុន្មាន ចងចាំបានអ្វីខ្លះ និងចេះមេរៀនបានកម្រិតណា?

២. តើសិស្សរៀនចេះទៅតាមកម្មវិធីសិក្សាដែលគ្រូបានបង្រៀនកម្រិតណា?

វង្វាយតម្លៃសិក្សាតាមបែបសរុប អាចរៀបចំឡើងតាមទ្រង់ទ្រាយផ្សេងៗ ដូចជាការប្រឡងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ការប្រឡងចេញ ការធ្វើរបាយការណ៍ ការធ្វើគម្រោងៗលៗ លទ្ធផលនៃវង្វាយតម្លៃទាំងនេះបង្ហាញពីចំណេះដឹងសរុប និងបំណិនសរុបដែលសិស្សទទួលបានក្នុងអំឡុងពេលនៃការសិក្សាក្នុងពេលកំណត់ណាមួយ ឬក្នុងការរៀនមេរៀនណាមួយៗ

លទ្ធផលនៃវង្វាយតម្លៃសិក្សាតាមបែបសរុប ដូចជាការធ្វើតេស្តអាចយកមកប្រើប្រាស់ ដើម្បីគ្រូរៀបចំការបង្រៀននៅថ្ងៃមុខៗ ចំណែកលទ្ធផលនៃការប្រឡងមានសារៈសំខាន់សម្រាប់សិស្សក្នុងការសិក្សានៅក្នុងភូមិសិក្សា ឬក្នុងការចូលរៀនកម្រិតឧត្តមសិក្សាៗ

## ១.៣. ភាពខុសគ្នារវាងវង្វាយតម្លៃទាំងពីរ

វង្វាយតម្លៃសិក្សាតាមដំណាក់កាលជាការវាស់ស្ទង់របៀបដែលសិស្សកំពុងរៀនមេរៀនអ្វីមួយ ចំណែកវង្វាយតម្លៃសិក្សាតាមបែបសរុបជាការវាស់ស្ទង់បរិមាណដែលសិស្សបានរៀនក្រោយពេលបញ្ចប់មេរៀន ឬវគ្គសិក្សាណាមួយៗ មធ្យោបាយងាយយល់ដើម្បីបែងចែកវង្វាយតម្លៃទាំងពីរប្រភេទនេះគឺវិធីសាស្ត្រតាមដំណាក់កាលជាការវាយតម្លៃដើម្បីរៀន ចំណែកវិធីសាស្ត្របែបសរុបជាការវាយតម្លៃលើការរៀនៗ

វង្វាយតម្លៃសិក្សាតាមបែបសរុបជួយឱ្យគ្រូបង្រៀនមើលឃើញកម្រិតដែលសិស្សបានរៀននៅក្នុងវគ្គសិក្សាជាក់លាក់ ដូចជាមួយឆមាសឬមួយឆ្នាំពេញៗ វង្វាយតម្លៃសិក្សាតាមបែបសរុបក៏អាចជួយគ្រូកំណត់បានថាសិស្សត្រៀមខ្លួនរួចហើយឬនៅដើម្បីឈានទៅកម្រិតខ្ពស់មួយទៀតៗ

ទោះបីវង្វាយតម្លៃសិក្សាតាមដំណាក់កាលហាក់ដូចធ្វើឡើងមិនគ្រប់ជ្រុងជ្រោយ ក៏ក្រុមអ្នកជំនាញអះអាងថាមិនមែនមានសារៈសំខាន់តិចជាងវង្វាយតម្លៃសិក្សាតាមបែបសរុបនោះទេ។ លោក David Bain ជំនាញផ្នែកនវានុវត្តន៍និងវិភាគ យល់ថា «វង្វាយតម្លៃសិក្សាតាមដំណាក់កាល ពិតជាជួយផ្លាស់ប្តូររបៀបរៀនរបស់សិស្ស។ គ្រូសម្រេចចិត្តលើការបង្រៀននិងកម្មវិធីសិក្សាដោយផ្អែកលើវង្វាយតម្លៃនេះ»។

## ១.៤. វង្វាយតម្លៃសិក្សាក្នុងកំណែទម្រង់វិស័យអប់រំ

ក្នុងឆ្នាំ២០១៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវ «កំណែទម្រង់អប់រំ» ដោយផ្តោតលើ «អាទិភាព៨ចំណុច»។ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកំណែទម្រង់៨ចំណុចខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានបំបែកអាទិភាពទាំងនេះ ជាការដ្ឋានកំណែទម្រង់ចំនួន១៥ចំណុចដែលក្នុងនោះ កំណែទម្រង់ទី ៦ គឺវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។

បន្ទាប់ពីបានអនុវត្តកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើអាទិភាពចំនួន ៨ ចំណុចអស់រយៈពេលមួយឆ្នាំមក នៅក្នុងឆ្នាំ ២០១៥ សន្និបាតអប់រំបានដាក់ចេញនូវ «ចក្ខុវិស័យកំណែទម្រង់អប់រំ» ដែលឈរលើសសរស្តម្ភ ៥ ដែលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គឺជាសសរស្តម្ភមួយសំខាន់។

សសរស្តម្ភទី៣–វង្វាយតម្លៃសិក្សា

- រៀបចំក្របខ័ណ្ឌវង្វាយតម្លៃសិក្សា (ការវាយតម្លៃក្នុងថ្នាក់ ការប្រឡងវង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ) និងការទទួលស្គាល់គុណភាពអប់រំ (ACC)
- ពង្រឹងការប្រឡងគ្រប់ប្រភេទ៖ បន្តកំណែទម្រង់ប្រឡងសញ្ញាបត្រមធ្យមសិក្សា ក្រោមពាក្យស្លោក «អ្នកចេះជាប់»
- ធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ៖ ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ ថ្នាក់ទី៦ ថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា

ពង្រឹងកម្មវិធីអំណាន និងគណិតវិទ្យា ពិសេសនៅថ្នាក់ទី១ ទី២ និងទី៣ អនុវត្តការសរសេរតាមអាន និងជំរុញឱ្យមានការវាយតម្លៃ និងប្រើប្រាស់លទ្ធផលដែលរកឃើញ

- ធ្វើតេស្តថ្នាក់តំបន់ និងអន្តរជាតិ៖ ការធ្វើតេស្តវង្វាយតម្លៃថ្នាក់តំបន់ Primary learning matrix (SEA-PLM) និងអន្តរជាតិ PISA
- ប្រើប្រាស់លទ្ធផលសិក្សានៃការវាយតម្លៃសិក្សារបស់សិស្ស ដើម្បីពង្រឹងគុណភាពសិក្សា
- ជំរុញការអភិវឌ្ឍសកម្មភាពអប់រំក្នុងសមាសភាគទាំង៥ និងកម្មវិធីសាលាកុមារមេត្រី ជាពិសេសសកម្មភាពរៀន និងបង្រៀន ដែលជាគ្រឹះនៃគុណភាពអប់រំ ដោយផ្សារភ្ជាប់នឹងជីវិតសហគមន៍។

## ១.៥. ភាពជាអ្នកដឹកនាំវង្វាយតម្លៃ

វង្វាយតម្លៃនៃលទ្ធផលសិក្សារបស់សិស្ស គឺជាសសរស្តម្ភទី៣នៃចក្ខុវិស័យស្តីពីកំណែទម្រង់វិស័យអប់រំនៅកម្ពុជា និងជាសមាសភាគយ៉ាងសំខាន់នៃការរៀននិងបង្រៀន។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុមតិ «ក្របខ័ណ្ឌវង្វាយតម្លៃសិក្សា» ដែលចែកចេញជាការវាយតម្លៃក្នុងថ្នាក់ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិនៅកម្ពុជាផ្តោតលើថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ការពង្រឹងកម្មវិធីអំណាន និងគណិតវិទ្យា ពិសេសនៅថ្នាក់ទី១ ទី២ និងទី៣ អនុវត្តការសរសេរតាមអាន និងជំរុញឱ្យនាយក និងគ្រូប្រើប្រាស់លទ្ធផលដែលរកឃើញក្នុងគោលដៅ កែលម្អការរៀន និងបង្រៀន។ ការធ្វើតេស្តថ្នាក់តំបន់ និងអន្តរជាតិរួមមានការធ្វើតេស្តវង្វាយតម្លៃថ្នាក់តំបន់ Primary learning matrix (SEA-PLM) និងអន្តរជាតិ Program in International Student Assessment (PISA)។

នាយកសាលាមានតួនាទីសំខាន់ ក្នុងការដឹកនាំការងារវង្វាយតម្លៃដើម្បី

សម្រេចបានការកែលម្អលទ្ធផលសិក្សារបស់សិស្ស ជាពិសេសក្នុងការអនុវត្ត កំណែទម្រង់នៅកម្រិតសាលារៀន (Fullan, 2010; Hollingworth, 2012)។ នាយកសាលា គឺជាតួអង្គសំខាន់ «ក្នុងការអនុវត្តកំណែទម្រង់វាយតម្លៃដែលផ្តោតលើការអនុវត្តវិធីសាស្ត្រសហការលើកកម្ពស់ការរិះរកក្នុងថ្នាក់រៀន» (Mansell et al. 2009, p. 22)។ ក្នុងន័យនេះ នាយកត្រូវអនុវត្តក្របខ័ណ្ឌវាយតម្លៃ ដោយអនុលោមតាមបរិបទនៃសាលានីមួយៗ។

កំណែទម្រង់វាយតម្លៃនៅប្រទេសសិង្ហបុរីផ្តោតលើ «វាយតម្លៃដើម្បីលើកកម្ពស់ការរៀន (Assessment for Learning (AfL)»។ ដើម្បីអនុវត្តក្របខ័ណ្ឌវាយតម្លៃនេះ នាយកសាលាត្រូវ៖

១. កំណត់ចំណុចខ្វះខាតរវាងវិធីសាស្ត្រវាយតម្លៃបច្ចុប្បន្ន និងគោលដៅ

២. កំណត់រយៈពេល និងឱកាស ដើម្បីកាត់បន្ថយចំណុចខ្វះខាត និង

៣ ធ្វើការជាមួយគ្រូ ដើម្បីពិនិត្យអនុវត្ត មតិយោបល់ ព័ត៌មានត្រឡប់ និងបង្កើតឱ្យមានការពិភាក្សា ក្នុងការអនុវត្តវិធានការថ្មី (H.Y. Tan and K. Tan in Wong, Hairon, and Ng, eds, 2019)។

សិង្ហបុរីបានអនុវត្តកំណែទម្រង់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដោយផ្តោតលើវិធីសាស្ត្រសរុប (holistic assessment-HA) គឺការប្រមូលទិន្នន័យ និងព័ត៌មានពីទិដ្ឋភាពផ្សេងៗរបស់សិស្សពីប្រភពផ្សេងៗគ្នា ក្នុងគោលដៅផ្តល់ព័ត៌មានត្រឡប់ ដើម្បីជួយដល់ការវិវឌ្ឍនៃការសិក្សារបស់សិស្ស។ វិធីសាស្ត្រសរុបកាត់បន្ថយសារៈសំខាន់លើការប្រឡងឆមាស (summative assessment) ហើយផ្តោតលើវាយតម្លៃជាប្រចាំ (formative assessment) របស់សិស្សក្នុងរយៈពេលឆ្នាំសិក្សា ដើម្បីលើកទឹកចិត្តសិស្ស និងបង្កើតភាពជឿជាក់ ដោយផ្តល់ដំបូន្មានដល់សិស្សម្នាក់ៗ ដើម្បីកែលម្អការសិក្សា។

# ជំពូកទី ២

# ក្របខណ្ឌវាយតម្លៃសិក្សា

## ២.១. ក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

*នៅឆ្នាំ ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវ «ក្របខ័ណ្ឌការវាយតម្លៃការសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ» ដើម្បីអាចវិនិច្ឆ័យលើគុណភាព ប្រសិទ្ធភាព គុណតម្លៃ និងតម្លៃរបស់ប្រព័ន្ធ កម្មវិធី ផលិតផល និងការអនុវត្តផ្សេងៗបាន។*

*តាមរយៈការវាយតម្លៃ គេអាចរកឃើញលទ្ធផលសិក្សា និងឥរិយាបថផ្សេងៗថែមទៀតផង (ឧទាហរណ៍ ការយល់ដឹងខ្លឹមសារ ជំនាញ អក្ខរភាពលេខនព្វន្ត ជំនាញត្រិះរិះ។ល។) ។*

*ការវាយតម្លៃមានសារៈសំខាន់ចំពោះជោគជ័យរបស់ប្រព័ន្ធអប់រំ ពីព្រោះការវាយតម្លៃអាចជួយដល់អ្នកអប់រំ និងភាគីពាក់ព័ន្ធសម្រេចចិត្តលើប្រព័ន្ធ កម្មវិធី ផលិតផល ឬការអនុវត្តទាំងនោះបាន។*

*ការវាយតម្លៃចាំបាច់ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព។*

## ដំហាននៃដំណើរការវាយតម្លៃទាំង៥




*គោលបំណងនៃការវាយតម្លៃ ៖*

*១. ដើម្បីផ្តល់ជាភស្តុតាងផ្សេងៗសម្រាប់ការសិក្សា ៖ ការវាយតម្លៃត្រូវតែអាចប្រមូលព័ត៌មានដែលពាក់ព័ន្ធទាំងអស់ដែលទាក់ទងនឹងប្រព័ន្ធ ព្រមទាំងបុគ្គល ស្ថាប័ន ឬអ្នកពាក់ព័ន្ធនានានៅក្នុងប្រព័ន្ធអប់រំ។*

*២. ដើម្បីជាព័ត៌មានសម្រាប់គោលនយោបាយ/ផែនការសកម្មភាព ៖ លទ្ធផលនៃការវាយតម្លៃ ត្រូវតែអាចយកមកប្រើដើម្បីជាព័ត៌មានដែលមានប្រយោជន៍ចំពោះគ្រូបង្រៀន ថ្នាក់ដឹកនាំសាលារៀន អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធទាំងអស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងឥទ្ធិពលរបស់ប្រព័ន្ធនោះ ក្នុងការអប់រំ។*

៣. ដើម្បីកែលម្អការបង្រៀន និងរៀន៖ លទ្ធផលនៃការវាយតម្លៃ និងការសន្និដ្ឋាន ត្រូវតែយកមកប្រើ ដើម្បីអភិវឌ្ឍជាអនុសាសន៍ ដែលអាចគាំទ្រ និងកែលម្អប្រព័ន្ធអប់រំ ជាពិសេសទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។

## ២.២. ការវាយតម្លៃផ្នែកក្រៅ និងការវាយតម្លៃផ្នែកក្នុង

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសុខដុមនីយកម្មលើការវាយតម្លៃទាំងអស់ ដោយបង្កើតជាក្របខ័ណ្ឌវាយតម្លៃ ដែលមានចំនួន១២ប្រភេទ ដែលបែកចេញជា៖ ការវាយតម្លៃផ្នែកក្រៅ និងការវាយតម្លៃផ្នែកក្នុង។

| ផ្នែកក្រៅ | | ផ្នែកក្នុង | |
|---|---|---|---|
| ការវាយតម្លៃកម្រិតអន្តរជាតិ និងថ្នាក់តំបន់ | ការវិនិច្ឆ័យទៅលើ ប្រព័ន្ធថ្នាក់ជាតិ | ការវាយតម្លៃបញ្ចប់កម្រិតថ្នាក់ ឬភូមិសិក្សា កម្រិតសាលារៀន និងថ្នាក់រៀន | ការវាយតម្លៃតាមដំណាក់កាលសម្រាប់អភិវឌ្ឍន៍កម្រិតសាលារៀន និងថ្នាក់រៀន |
| PISA សម្រាប់អភិវឌ្ឍ (PISA-D)<br>តេស្តវង្វាយតម្លៃការសិក្សាសម្រាប់សិស្សបឋមសិក្សានៅអាស៊ីអាគ្នេយ៍ (SEA-PLM) | តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ<br>ប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២<br>តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង (EGRA)<br>តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង (EGRA) | ប្រឡងថ្នាក់ជាតិ ថ្នាក់ទី៩<br>ប្រឡងឡើងថ្នាក់<br>ប្រឡងឆមាស/អំណានស្ទាត់ | ការវាយតម្លៃកម្រិតមត្តេយ្យ / ការត្រៀមលក្ខណៈចូលសាលា<br>ប្រឡងប្រចាំខែ<br>ការវាយតម្លៃជាប្រចាំកម្រិតថ្នាក់រៀន |


ផ្ទៃក្រៅ
(ការវាយតម្លៃជាប្រព័ន្ធ
អនុវត្តដោយនាយកដ្ឋានជំនាញ)
• ការវាយតម្លៃសិក្សាជាអន្តរជាតិ (PISA-D)
• ការវាយតម្លៃសិក្សានៅថ្នាក់តំបន់ (SEA-PLM)
• ការវាយតម្លៃសិក្សានៅថ្នាក់ជាតិ (៣, ៦, ៨ និង១១)
• តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង (EGRA) តេស្តវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង
• ការប្រឡងថ្នាក់ទី១២
• ការប្រឡងថ្នាក់ទី៩
• (បច្ចុប្បន្ន «ធ្វើផ្ទៃក្នុង»)
ការវាយតម្លៃទ្រង់ទ្រាយធំកម្រិតប្រព័ន្ធ
ការប្រឡង
មន្ទីរអប់រំ
ការវាយតម្លៃកម្រិតសាលា
ការវាយតម្លៃកម្រិតថ្នាក់រៀន
• ការប្រឡងឆមាស (អំណានស្ទាត់)
• ការវាយតម្លៃថ្នាក់មត្តេយ្យ/ត្រៀមលក្ខណៈចូលសាលា
• ប្រឡងឡើងថ្នាក់
• ការវាយតម្លៃប្រចាំខែ
• ការវាយតម្លៃក្នុងពេលសិក្សាជាប្រចាំ
ផ្ទៃក្នុង
ការវាយតម្លៃការសិក្សារបស់សិស្ស អនុវត្តដោយ
គ្រូនិងសាលា គាំទ្រដោយ កម្រង និងការិយាល័យស្រុក
ការកែលម្អ កម្មវិធីសិក្សា ការរៀន និងការវាយតម្លៃ

១. សំណុំទីមួយនៃការវាយតម្លៃគឺការវាយតម្លៃកម្រិតថ្នាក់រៀនដែលត្រូវបានអនុវត្តជាប្រចាំ និងដឹកនាំដោយគ្រូ។ ការវាយតម្លៃទាំងនេះផ្តោតសំខាន់លើការអភិវឌ្ឍ និងការសិក្សារបស់សិស្ស។ ការប្រើប្រាស់ការវាយតម្លៃទាំងនេះ អាចប្រកបដោយអត្ថន័យតាមរយៈការគាំទ្របច្ចេកទេសពីថ្នាក់កម្រង និង/ ឬថ្នាក់ស្រុក។ នាយកសាលាគួរជំរុញនិងពង្រឹងការវាយតម្លៃនេះ តាមរយៈការពិនិត្យតាមដានជាប្រចាំ ឬក៏ភ្ជាប់ការវាយតម្លៃនេះទៅនឹងការវាយតម្លៃដោយសាលាខ្លួនឯង ដែលបច្ចុប្បន្នការធ្វើដូច្នេះតម្រូវឱ្យមាននៅក្នុងការពិនិត្យតាមដានរបស់ក្រុមបណ្តុះបណ្តាល និងពិនិត្យតាមដានថ្នាក់ស្រុក (DTMT)។

២. សំណុំវាយតម្លៃទីពីរគឺការវាយតម្លៃនៅកម្រិតសាលាជាមួយនឹងគោលបំណងវិនិច្ឆ័យ និងដើម្បីឱ្យសិស្សឆ្លងកម្រិតថ្នាក់ និងភូមិសិក្សា។ ប៉ុន្តែរបៀបអនុវត្តការវាយតម្លៃនេះ មិនបានផ្សារភ្ជាប់ទំនាក់ទំនងច្បាស់លាស់ជាមួយនឹងការងាររបស់ថ្នាក់កម្រង ឬការងាររបស់ការិយាល័យអប់រំស្រុក (DoE) ឡើយ។ ភាពដូចគ្នាឬឯកសណ្ឋានភាព និងគុណភាពរបស់ការវាយតម្លៃទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ បើតាមទំនោរ និងលក្ខណៈនៃការវាយតម្លៃរបស់សំណុំនេះ។ ដូច្នេះក្រៅពីនាយកសាលា ថ្នាក់កម្រងនិងថ្នាក់ស្រុកគួរតែដើរតួនាទីពិនិត្យតាមដានឱ្យបានល្អនៅក្នុងការងារនេះ។

៣. ការវាយតម្លៃការសិក្សារបស់សិស្សក្នុងសំណុំទីបី គឺជាការវាយតម្លៃបញ្ចប់ភូមិសិក្សាដែលអនុវត្តនៅកម្រិតថ្នាក់ទី៩ និងទី១២ តាមរយៈការប្រឡងថ្នាក់ជាតិដើម្បីដំឡើងថ្នាក់សិស្សទៅកាន់ថ្នាក់ទី១០ និងទៅសកលវិទ្យាល័យ។ បច្ចុប្បន្ន ការប្រឡងថ្នាក់ទី១២ ត្រូវបានរៀបចំទូទាំងប្រទេស ហើយដឹកនាំដោយនាយកដ្ឋានកិច្ចការប្រឡង (DEA) ចំណែកឯការប្រឡងថ្នាក់ទី៩ ជាការវាយតម្លៃផ្ទៃក្នុង ដោយឱ្យសាលានីមួយៗជាអ្នកអនុវត្តការវាយតម្លៃនេះ។ នេះជាហេតុដែលនាំឱ្យមានការបារម្ភខ្លាំង ចំពោះការប្រៀបធៀបពិន្ទុពីសាលាមួយទៅសាលាមួយទៀត សម្រាប់ការប្រឡងថ្នាក់ទី៩នេះ។ ដូច្នេះ ភាពដូចគ្នាឬឯកសណ្ឋានភាព និងគុណភាពរបស់ការវាយតម្លៃទាំងនេះ គឺជាចំណុច

សំខាន់ខ្លាំងណាស់។

៤. ការវាយតម្លៃក្នុងសំណុំចុងក្រោយ គឺជាការវាយតម្លៃទ្រង់ទ្រាយធំ ដឹកនាំដោយនាយកដ្ឋានធានាគុណភាពអប់រំ ដូចជា ៖ (១) ការវាយតម្លៃសិស្សជាអន្តរជាតិ (PISA-D) (២) ការវាយតម្លៃសិស្សនៅថ្នាក់តំបន់ (SEA-PLM) (៣) ការវាយតម្លៃថ្នាក់ជាតិ (ថ្នាក់ទី ៣, ៦, ៨ & ១១) (៤) តេស្តវាយតម្លៃអំណានថ្នាក់ដំបូង (EGRA) (៥) តេស្តវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង (EGMA)។ លទ្ធផលបានមកពីការវាយតម្លៃនេះ យកទៅប្រើសម្រាប់ការបង្កើតគោលនយោបាយជាប្រព័ន្ធ ការកសាងផែនការ និងកិច្ចអន្តរាគមន៍ផ្សេងៗ។

**លទ្ធផលតាមថ្នាក់ និងឆ្នាំ**

| ល.រ | ឆ្នាំ | ភាគរយអានត្រូវ | | | | ពិន្ទុ | | |
|---|---|---|---|---|---|---|---|---|
| | | អំណាន | សំណេរ | គណិត | រូបវិទ្យា | អំណាន | គណិត | រូបវិទ្យា |
| ១ | ថ្នាក់ទី៣-២០១៥ | ៤២.៧ | ៣០.៤ | ៤១.០ | | ៥០០.០ | ៥០០.០ | |
| ២ | ថ្នាក់ទី៣- ២០១៩ | ៤២.៦ | ២៨.១ | ៤០.៤ | | ៥០២.៦ | ៥០១.៤ | |
| ៣ | ថ្នាក់ទី៦-២០១៣ | ៦២.២ | ២៨.៩ | ៤៣.៤ | | ៥០០.០ | ៥០០.០ | |
| ៤ | ថ្នាក់ទី៦-២០១៦ | ៤១.៧ | ៤៥.៣ | ៤៨.៣ | | ៤៩២.៨ | ៤៩៣.២ | |
| ៥ | ថ្នាក់ទី៨-២០១៤ | ៧៣.៨ | ២៨.៣ | ៤៤.០ | ៥២.៨ | ៥០០.០ | ៥០០.០ | ៥០០.០ |
| ៦ | ថ្នាក់ទី៨-២០១៧ | ៦៤.៨ | ៣១.២ | ៤៧.៣ | ៤៥.៥ | ៤៩៥.៤ | ៤៩៣.៥ | ៤៩៧.២ |
| ៧ | ថ្នាក់ទី១១-២០១៨ | ៥៧.៣ | ៥៧.៦ | ៣៧.៧ | ៣៤.៥ | ៥០០.០ | ៥០០.០ | ៥០០.០ |

**លទ្ធផលតាមថ្នាក់ និងឆ្នាំ**

| ល.រ | មុខវិជ្ជា | ថ្នាក់ទី៣ ២០១៥ | ថ្នាក់ទី៣ ២០១៩ | ថ្នាក់ទី៦ ២០១៣ | ថ្នាក់ទី៦ ២០១៦ | ថ្នាក់ទី៨ ២០១៤ | ថ្នាក់ទី៨ ២០១៧ | ថ្នាក់ទី១១ ២០១៥ |
|---|---|---|---|---|---|---|---|---|
| ១ | អំណាន | ៤២.៧ | ៤២.៦ | ៦២.២ | ៦១.៧ | ៧៣.៨ | ៦៤.៨ | ៥៧.៣ |
| ២ | សំណេរ | ៣០.៤ | ២៨.១ | ២៨.៩ | ៤៥.៣ | ២៨.៣ | ៣១.២ | ៥៧.៦ |
| ៣ | គណិត | ៤១.០ | ៤០.៤ | ៤៣.៤ | ៤៨.៣ | ៤៤.០ | ៤៧.៣ | ៣៧.៧ |
| ៤ | វិទ្យាសាស្ត្រ | | | | | ៥២.៨ | ៤៥.៥ | ៣៤.៥ |

# សង្ខេបលទ្ធផលតាមឆ្នាំ

| | | ថ្នាក់ទី៣ | ពិន្ទុ | ថ្នាក់ទី៦ | ពិន្ទុ | ថ្នាក់ទី៨ | ពិន្ទុ | ថ្នាក់ទី ១១ | ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|
| ២០១៣ | អំណាន | | | ៦២.២ | ៥០០.០ | | | | |
| | សំណេរ | | | ២៨.៩ | | | | | |
| | គណិតវិទ្យា | | | ៤៣.៤ | ៥០០.០ | | | | |
| ២០១៤ | អំណាន | | | | | ៧៣.៨ | ៥០០.០ | | |
| | សំណេរ | | | | | ២៨.៣ | | | |
| | គណិតវិទ្យា | | | | | ៤៤.០ | ៥០០.០ | | |
| | រូបវិទ្យា | | | | | ៥២.៨ | ៥០០.០ | | |
| ២០១៥ | អំណាន | ៤២.៧ | ៥០០.០ | | | | | | |
| | សំណេរ | ៣០.៤ | | | | | | | |
| | គណិតវិទ្យា | ៤១.០ | ៥០០.០ | | | | | | |
| ២០១៦ | អំណាន | | | ៦១.៧ | ៤៩២.៨ | | | | |
| | សរសេរ | | | ៤៥.៣ | | | | | |
| | គណិតវិទ្យា | | | ៤៨.៣ | ៤៩៣.២ | | | | |
| ២០១៧ | អំណាន | | | | | ៦៤.៨ | ៤៩៥.៤ | | |
| | សំណេរ | | | | | ៣១.២ | | | |
| | គណិតវិទ្យា | | | | | ៤៧.៣ | ៤៩៣.៥ | | |
| | រូបវិទ្យា | | | | | ៤៥.៥ | ៤៩៧.២ | | |
| ២០១៨ | អំណាន | | | | | | | ៥៧.៣ | ៥០០.០ |
| | សំណេរ | | | | | | | ៥៧.៦ | ៥០០.០ |
| | គណិតវិទ្យា | | | | | | | ៣៧.៧ | ៥០០.០ |
| | រូបវិទ្យា | | | | | | | ៣៤.៥ | ៥០០.០ |
| ២០១៩ | អំណាន | ៤២.៦ | ៥០២.៦ | | | | | | |
| | សំណេរ | ២៨.១ | | | | | | | |
| | គណិតវិទ្យា | ៤០.៤ | ៥០១.៤ | | | | | | |

# លទ្ធផលតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៦ ឆ្នាំ២០២១




## ភត្តាភេទ






*លទ្ធផលនៃការវិភាគបង្ហាញថា សិស្សមកពីតំបន់ប្រជុំជន ទទួលបានលទ្ធផលសិក្សាល្អប្រសើរជាងសិស្សមកពីតំបន់ជនបទទាំងភាសាខ្មែរ (អំណាន និងសំណេរ) និងគណិតវិទ្យា។*



**គណិតវិទ្យា៖ រួម**




## ២.៣. កម្មវិធីអន្តរជាតិស្ដីពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស សម្រាប់ប្រទេសកំពុងអភិវឌ្ឍ(PISA-D)

*តេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ* (PISA-D) *គឺជាគម្រោងសាកល្បងរយៈពេល៤ឆ្នាំ* (២០១៥-២០១៨) *ដែលរៀបចំឡើងដោយ* OECD។

PISA *ត្រូវបានបង្កើតឡើងដោយ* OECD *នៅក្នុងឆ្នាំ១៩៩៧ ដើម្បីវាយតម្លៃសិស្សអាយុ១៥ឆ្នាំ ស្ដីពីភាពស្ទាត់ជំនាញក្នុងការអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ និងរាស់វែងបំណិនរបស់សិស្ស ក្នុងការអនុវត្តអ្វីដែលគេបានរៀនក្នុងសាលា នៅក្នុងស្ថានភាពពិតក្នុងជីវិត។ ចំនួនប្រទេសដែលចូលរួមក្នុង* PISA *បានកើនឡើងពី៤៤ ក្នុងឆ្នាំ២០០០ ដល់៨២ ក្នុងឆ្នាំ២០១៨ ដែលក្នុងនោះមានប្រទេសដែលមានប្រាក់ចំណូលមធ្យមចំនួន៤៤ បានចូលរួម។*

*ចាប់តាំងពីឆ្នាំ ២០១៤ មក* OECD *បានសាកល្បងធ្វើវាយតម្លៃ* PISA

សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដែលមានឈ្មោះថា PISA-D ដែលមានប្រទេស ៩ចូលរួម គឺ ៖ កម្ពុជា និងប៊ូតង់ នៅអាស៊ី សេណេហ្គាល់ និងសំប៊ី នៅអាហ្វ្រិក និងអេក្វាឌ័រ ហ្គាតេម៉ាឡា ហុងឌូរ៉ាស់ ប៉ារ៉ាហ្គាយ និងប៉ាណាម៉ា នៅអាមេរិក-ឡាទីន ដែលជាប្រទេសមានប្រាក់ចំណូលទាប និងមធ្យម។ ធនាគារពិភព-លោក និងវិទ្យាស្ថានកូរ៉េសម្រាប់កម្មវិធីសិក្សា និងវាយតម្លៃKICE ផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់វាយតម្លៃនេះ។

## សំណាកសម្រាប់វាយតម្លៃ PISA-D

កម្ពុជាមានសាលារៀនចំនួន ១២.៨៨៩ មានសិស្សចំនួន ៣.០៧៧.៦៦០ នាក់ រៀនពីថ្នាក់ទី១ ដល់ទី១២ ដែលក្នុងនោះសិស្សស្រីមានចំណែក ៤៩,២៦%។ សិស្សរៀននៅកម្រិតបឋមសិក្សាមានចំនួន ២.០២២.០៦១ នាក់ នៅអនុវិទ្យាល័យមានចំនួន ៥៨៥.៩៧១ នាក់ និងនៅវិទ្យាល័យចំនួន ២៧៩.៤៨០ នាក់។ ពោល គឺអត្រាបោះបង់ចោលការសិក្សា ក្នុងការឆ្លងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិមានកម្រិតខ្ពស់។

នៅក្នុងការធ្វើវាយតម្លៃ គេបានជ្រើសរើសសិស្សចំនួន ៥,១៦២ នាក់ និងគ្រូចំនួន ៤,២៦៣ នាក់ពីសាលាចំនួន១៧០ សាលា មកធ្វើវាយតម្លៃ ដោយជ្រើសរើសសិស្សអាយុ១៥ឆ្នាំ ចំនួន៤១នាក់ក្នុង ១ សាលា មកធ្វើតេស្តក្នុងរយៈពេល២ម៉ោង បន្ទាប់មកត្រូវបំពេញកម្រងសំណួរពាក់ព័ន្ធនឹងស្ថានភាពផ្ទាល់ខ្លួន ជីវភាពគ្រួសារ ការសិក្សា ការបង្រៀនរបស់គ្រូ។ល។

នាយកសាលា និងគ្រូក៏ត្រូវបំពេញកម្រងសំណួរពាក់ព័ន្ធនឹងស្ថានភាពសាលារៀន និងព័ត៌មានទាក់ទងនឹងមាតាបិតា គ្រូបង្រៀន និងការចូលរួមរបស់សហគមន៍។

គំរូវាយតម្លៃនេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់ក្របខ័ណ្ឌវិភាគនៃម៉ូឌែល វិបុលភាពនៃការអប់រំ (Education Prosperity, Willms, 2015) ៖ (១) មូលដ្ឋានគ្រឹះនៃភាពជោគជ័យ ៖ (i) បរិកាសនៃការអប់រំបរិយាបន្ន (ii) ម៉ោង

សិក្សា (iii) គុណភាពបង្រៀន (iv)  ការគាំទ្រពីគ្រួសារ និងសហគមន៍ និង(v) ធនធាន និង (២) លទ្ធផលសម្រេចនៃវិបុលភាព ៖ (i) សមិទ្ធផលសិក្សាសម្រេចបាន (ii) លទ្ធផលសិក្សា (iii) សុខភាពនិងសុខុមាលភាព (iv) ឥរិយាបថចំពោះសាលារៀន និងការសិក្សារបស់សិស្ស។



## កម្រិតសមត្ថភាពទាំង៦នៃវង្វាយតម្លៃ PISA-D

វង្វាយតម្លៃ PISA-D សង្កត់ធ្ងន់លើសមត្ថភាពរបស់សិស្សក្នុងការអនុវត្តចំណេះដឹង និងបំណិនរបស់ខ្លួនក្នុងជីវិតជាក់ស្តែង ៖ សមត្ថភាព ក្នុងការវិភាគ ផ្តល់ទឡ្ហីករណ៍ និងប្រាស្រ័យទាក់ទង (Communicate) ប្រកបដោយប្រសិទ្ធភាព ដោយពួកគេត្រូវកំណត់បកស្រាយ និងដោះស្រាយបញ្ហាក្នុងស្ថានភាពផ្សេងៗ។ និយមន័យនៃពាក្យមានដូចតទៅ ៖

អក្ខរកម្មអំណាន (Reading literacy) ៖ គឺជាសមត្ថភាពយល់ ប្រើប្រាស់ ពិចារណាលើអត្ថបទសរសេរ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍចំណេះដឹង និងសក្តានុពលរបស់ខ្លួន និងចូលរួមក្នុងសង្គម។

អក្ខរកម្មគណិតវិទ្យា (Mathematical literacy) ៖ គឺជាសមត្ថភាពចេះរូបមន្តប្រើប្រាស់ និងបកស្រាយគណិតវិទ្យា ដោយប្រើប្រាស់ទស្សនាទាន និងឧបករណ៍ ដើម្បីពិពណ៌នា ពន្យល់ និងព្យាករបាតុភូត ចេះវិនិច្ឆ័យត្រឹមត្រូវ និងសម្រេចចិត្តជាពលរដ្ឋដែលមានការត្រិះរិះពិចារណា។

អក្ខរកម្មវិទ្យាសាស្ត្រ (Scientific literacy) ៖ គឺជាសមត្ថភាពយល់ដឹងពីបញ្ហាវិទ្យាសាស្ត្រ និងគំនិតវិទ្យាសាស្ត្រ ជាពលរដ្ឋដែលមានការត្រិះរិះពិចារណា ដែលអាចយល់ដឹងពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងមានសមត្ថភាពក្នុងការពន្យល់បាតុភូតវិទ្យាសាស្ត្រ វាយតម្លៃ និងរៀបចំគម្រោងស្រាវជ្រាវ វិទ្យាសាស្ត្រ និងបកស្រាយទិន្នន័យវិទ្យាសាស្ត្រ។

ភាពស្ទាត់ជំនាញរបស់សិស្ស (Student proficiency) ៖ គឺជាភាពស្ទាត់ជំនាញតាមកម្រិតចំនួន ៦ ដែលកម្រិត ៦ គឺជាកម្រិតខ្ពស់បំផុត និងកម្រិត ១ និងទាបជាងមួយ គឺជាកម្រិតទាបបំផុត។ កម្រិត២ គឺជាកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញ ដែលសិស្សអាចបង្ហាញសមត្ថភាពចូលរួមក្នុងជីវិត ជាសិស្សដែលអាចរៀនបន្ត ជាពលករ និងជាពលរដ្ឋ។

គោលដៅអភិវឌ្ឍន៍អប់រំប្រកបដោយចីរភាព OECD មធ្យម

| កម្រិត | ពិន្ទុអំណាន | ពិន្ទុគណិតវិទ្យា | ពិន្ទុវិទ្យាសាស្ត្រ |
|---|---|---|---|
| 1c<br>1b<br>1a | ១៨៩<br>២៦២<br>៣៣៥ | ២៣៦<br>២៩៥<br>៣៥៨ | ១៨៦<br>២៦០<br>៣៣៥ |
| ២ | ៤០៧ | ៤២០ | ៤១០ |
| ៣ | ៤៨០ | ៤៨២ | ៤៨៤ |
| ៤ | ៥៥៣ | ៥៤៥ | ៥៥៩ |
| ៥ | ៦២៦ | ៦០៧ | ៦៣៣ |
| ៦ | ៦៩៨ | ៦៦៩ | ៧០៨ |

នៅក្នុងប្រទេសកម្ពុជា៨% នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង១០%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសអេក្វាឌ័រ៤៩%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង២៩%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសក្វាតេម៉ាឡា ៣០%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង១១%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសហុងឌុយរ៉ាស់ ៣០%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង១៥%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសប៉ារ៉ាហ្គាយ៣២%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង៨%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសសេណេហ្គាល់៩%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង៨%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាន

នៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

នៅក្នុងប្រទេសសំប៊ី ៥%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងការអាន និង២%នៃសិស្សសម្រេចបានកម្រិតមូលដ្ឋាននៃភាពស្ទាត់ជំនាញក្នុងគណិតវិទ្យា។

## សមត្ថភាពកម្រិតទី២នៃមុខវិជ្ជា អំណាន

លំហាត់មួយចំនួននៅកម្រិតនេះ តម្រូវឱ្យអ្នកអានស្វែងរកព័ត៌មានមួយ ឬច្រើន និងធ្វើការសន្និដ្ឋាន ផ្អែកលើលក្ខខណ្ឌផ្សេងៗ។

លំហាត់ផ្សេងទៀត តម្រូវឱ្យអ្នកអានស្គាល់គំនិតសំខាន់ក្នុងអត្ថបទ ស្វែងយល់អំពីទំនាក់ទំនងនៃព័ត៌មាន ឬបកស្រាយអត្ថន័យនៅក្នុងផ្នែកតូចៗនៃអត្ថបទ ដែលមានព័ត៌មានមិនលេចធ្លោ ហើយអ្នកអានត្រូវធ្វើការសន្និដ្ឋានកម្រិតទាប។

លំហាត់នៅកម្រិតនេះអាចពាក់ព័ន្ធនឹងការប្រៀបធៀប ឬភាពផ្ទុយគ្នាដោយផ្អែកលើលក្ខណៈពិសេសតែមួយនៅក្នុងអត្ថបទ។

នៅកម្រិតនេះ លំហាត់បែបឆ្លុះបញ្ចាំងមានលក្ខណៈទូទៅ និងតម្រូវឱ្យអ្នកអានធ្វើការប្រៀបធៀប ឬតភ្ជាប់រវាងអត្ថបទនិងចំណេះដឹងខាងក្រៅដោយប្រើបទពិសោធន៍ និងឥរិយាបថផ្ទាល់ខ្លួនក្នុងការឆ្លើយសំណួរ។

## សមត្ថភាពកម្រិតទី២នៃមុខវិជ្ជា គណិតវិទ្យា

នៅកម្រិតទី២ សិស្សអាចបកស្រាយនិងស្គាល់ស្ថានភាពក្នុងបរិបទផ្សេងៗដែលតម្រូវមិនឱ្យមានអ្វីលើសពីការសន្និដ្ឋានដោយផ្ទាល់ឡើយ។

សិស្សអាចទាញយកព័ត៌មានពីប្រភពតែមួយ និងប្រើប្រាស់រូបមន្តឬទ្រឹស្តីណាមួយមកបង្ហាញ។

សិស្សនៅកម្រិតនេះអាចអនុវត្តប្រមាណវិធី រូបមន្ត នីតិវិធី ឬទ្រឹស្តីដើម្បីដោះស្រាយលំហាត់ពាក់ព័ន្ធនឹងចំនួនគត់វិជ្ជមាន។

សិស្សមានសមត្ថភាពបកស្រាយលទ្ធផលងាយៗ។

## សមត្ថភាពកម្រិតទី២នៃមុខវិជ្ជា វិទ្យាសាស្ត្រ

នៅកម្រិតទី២ សិស្សអាចប្រើចំណេះដឹងវិទ្យាសាស្ត្រនិងវិធានដោះស្រាយលំហាត់ ដើម្បីកំណត់ការពន្យល់បែបវិទ្យាសាស្ត្រដ៏សមស្របមួយ បកស្រាយទិន្នន័យ និងកំណត់សំណួរដែលនឹងត្រូវលើកឡើង នៅក្នុងគម្រោងនៃការពិសោធសាមញ្ញមួយ។

សិស្សអាចប្រើចំណេះដឹងវិទ្យាសាស្ត្រជាមូលដ្ឋាន ឬប្រចាំថ្ងៃ ដើម្បីធ្វើការសន្និដ្ឋានដ៏ត្រឹមត្រូវមួយ ពីសំណុំទិន្នន័យងាយៗ។

សិស្សបង្ហាញចំណេះដឹងបញ្ញត្តិវិទ្យាសាស្ត្រជាមូលដ្ឋាន ដោយអាចកំណត់សំណួរសម្រាប់ស្រាវជ្រាវឬរុករកតាមបែបវិទ្យាសាស្ត្រ។

**អំណាន**



សិស្សកម្ពុជា ទទួលបានពិន្ទុលើមុខវិជ្ជាអំណានទាបជាងកម្រិតទី២ របស់ PISA-D និងព្រមទាំងទាបជាងពិន្ទុរបស់សិស្សមកពីប្រទេសជាសមាជិក PISA-D ជាមធ្យម។

## វិទ្យាសាស្ត្រ




សិស្សកម្ពុជាទទួលបានពិន្ទុលើមុខវិជ្ជាវិទ្យាសាស្ត្រទាបជាងកម្រិតទី២ របស់ PISA-D និងព្រមទាំងទាបជាងពិន្ទុរបស់សិស្សមកពីប្រទេសជាសមាជិក PISA-D ជាមធ្យម។

## គណិតវិទ្យា




*សិស្សកម្ពុជាទទួលបានពិន្ទុលើមុខវិជ្ជា គណិតវិទ្យាប្រហាក់ប្រហែលនឹងពិន្ទុរបស់សិស្សមកពីប្រទេសជាសមាជិក PISA-D ជាមធ្យម។*

## ប្រៀបធៀបនឹងទ្វីបអាហ្វ្រិក និងអាមេរិកឡាទីន

*សិស្សកម្ពុជាទទួលបានពិន្ទុ ខ្ពស់ជាងសេណេហ្គាល់និងសំប៊ី លើគ្រប់មុខវិជ្ជា និងប្រហាក់ប្រហែលនឹងមធ្យមភាគរបស់ PISA-D លើមុខវិជ្ជាគណិតវិទ្យា។ ប៉ុន្តែពិន្ទុអំណានរបស់សិស្សនៅកម្ពុជាទាបជាងគេក្នុងចំណោមមុខវិជ្ជាទាំងបី។*




## ប្រៀបធៀបនឹងសមត្ថភាពមូលដ្ឋាន

*សិស្សកម្ពុជាប្រហែល៨% មានសមត្ថភាពកម្រិតមូលដ្ឋានលើមុខវិជ្ជាអំណាន និងសិស្សប្រហែល១០% មានសមត្ថភាពមូលដ្ឋាន លើមុខវិជ្ជាគណិតវិទ្យា។*



**មូលហេតុនៃលទ្ធផលសិក្សាទាប**

- *សិស្សមួយចំនួនមករៀនមិនទៀងទាត់ (អវត្តមាន)*
- *សិស្សមួយចំនួនមករៀនយឺត*
- *គ្រូអវត្តមាន និងមកបង្រៀនយឺត*
- *មាតាបិតាមិនយកចិត្តទុកដាក់ត្រួតពិនិត្យនៅផ្ទះ*

**វិធានការឆ្លើយតប**

- *កំណែទម្រង់គោលនយោបាយ ៖ ថ្នាក់កណ្ដាល*
- *សៀវភៅសិក្សាគោល*
- *ស្តង់ដាគ្រូ និងនាយក*
- *ការរៀបចំគ្រូឧទ្ទេសថ្នាក់ជាតិ ៖ វិធីសាស្ត្របង្រៀន*
- *កំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូ ៖ ការពិនិត្យឡើងវិញនូវកម្មវិធីបណ្ដុះបណ្ដាលគ្រូ*
- *គុណវុឌ្ឍិគ្រូ*
- *វិធីសាស្ត្របង្រៀនក្នុងបរិបទថ្មី*
- *បំណិន*
- *បំណិតទន់*
- *កំណែទម្រង់សាលារៀន*
- *ការគ្រប់គ្រងសាលារៀន*
- *ការបង្រៀនរបៀបធ្វើតេស្តនៅសាលាគោលដៅ*
- *សាលាជំនាន់ថ្មី*
- *ឯកសារបង្រៀននិងរៀន និងសម្ភារៈឧបទេស*

**បញ្ហាសំខាន់**

*ការដែលបានចូលរៀន ជាសំណាងរបស់សិស្ស មានន័យថាសិស្ស*

*សប្បាយចិត្តពេលមានឱកាសចូលរៀន។*

*ប៉ុន្តែសាលារៀន ហាក់ដូចជាពុំទាន់ផ្តល់ឱ្យសិស្សរៀន ប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឡើយ ដោយសារបញ្ហាបាត់ម៉ោងនិងគុណភាពបង្រៀន។*

**សេចក្តីសន្និដ្ឋាន**

*សិស្សសប្បាយចិត្តពេលមានឱកាសចូលរៀន។ ប៉ុន្តែសាលារៀន ហាក់ដូចជាពុំទាន់អភិវឌ្ឍឱ្យសិស្សមានសមត្ថភាព និងសុខុមាលភាពល្អប្រសើរតាមតែអាចធ្វើបាន។*

*ប៉ុន្តែ យោងតាមការចំណាយលើការអប់រំនាពេលបច្ចុប្បន្ន កម្ពុជានឹងអាចអភិវឌ្ឍការអប់រំឱ្យកាន់តែប្រសើរនាពេលអនាគត។*

## ២.៤. ខ្សែរវាយតម្លៃថ្នាក់តំបន់ SEA-PLM



SEA-PLM ជាគំនិតផ្តួចផ្តើមថ្នាក់តំបន់របស់អង្គការរដ្ឋមន្ត្រីអប់រំអាស៊ាន (SEAMEO) និងការិយាល័យអង្គការយូនីសេហ្វតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (UNICEF EAPRO) គាំទ្របច្ចេកទេសដោយក្រុមប្រឹក្សាអូស្ត្រាលី សម្រាប់វង្វាយតម្លៃ និងការស្រាវជ្រាវអប់រំ (ACER) ដោយទទួលបានការឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វកម្ពុជា (UNICEF Cambodia)។

មានប្រទេសចូលរួមចំនួន៦ នៅជុំទី១ ៖ កម្ពុជា ឡាវ ម៉ាឡេស៊ី ហ្វីលីពីន មីយ៉ានម៉ា និងវៀតណាម។

SEA-PLM រៀបចំឡើងស្របតាមកម្មវិធីសិក្សារបស់សិស្សថ្នាក់ទី៥ ផ្តោតលើផ្នែកអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល។

SEA-PLM បានប្រមូលព័ត៌មានពីសិស្ស មាតាបិតាសិស្ស គ្រូបង្រៀន និងនាយកសាលា អំពីការរស់នៅ បទពិសោធន៍ពីសាលារៀន និងបរិបទបង្រៀនជាក់ស្តែងទាក់ទងនឹងការរៀនសូត្ររបស់សិស្ស។



**គោលបំណង SEA-PLM**

*ផ្តល់ទិន្នន័យច្បាស់លាស់ដើម្បីពិនិត្យតាមដាន និងដឹងពីកម្រិតយល់ដឹងរបស់ក្រុមសិស្សផ្សេងៗ និងផ្តើមអនុវត្តសកម្មភាពដើម្បីពង្រឹងគុណភាពអប់រំឱ្យប្រសើរឡើងគ្រប់ផ្នែកក្នុងប្រព័ន្ធអប់រំទាំងមូល។*

*ពង្រឹងសមត្ថភាពរៀបចំវិភាគទិន្នន័យ និងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សរបស់ប្រទេសដែលបានចូលរួម កម្រិតតំបន់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។*

*ពង្រឹងសមត្ថភាពប្រើប្រាស់លទ្ធផលសិក្សារបស់សិស្សដែលបានពីទិន្នន័យវាយតម្លៃសិក្សាដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។*

*ពង្រឹងសមាហរណកម្មអាស៊ានតាមរយៈយន្តការវាយតម្លៃកម្រិតតំបន់លើសិស្សថ្នាក់ទី៥ លើផ្នែកអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល។*

**លទ្ធផលសិក្សាផ្នែកអំណាន សំណេរ និងគណិតវិទ្យា**



## កម្រិតសមត្ថភាពសិស្ស លើផ្នែកអំណានក្នុងតេស្ត SEA-PLM

| កម្រិតសមត្ថភាព | សេចក្ដីពណ៌នាកម្រិតចំណេះដឹងសិស្សអាចធ្វើបាន |
|---|---|
| **កម្រិត៦ឡើង (ពិន្ទុ ៣១៧ ឡើង) ១១%** | **យល់អត្ថបទដោយស៊ាំជាមួយនឹងរចនាសម្ព័ន្ធក្នុងអត្ថបទ និងបំពេញព័ត៌មានបាន** សមត្ថភាពសិស្សលើសពីកម្រិតទី៥នេះ អាចយល់ពីអត្ថបទដែលមានរចនាសម្ព័ន្ធសាមញ្ញ និងអាចរកព័ត៌មានទាក់ទងនឹងគំនិតសំខាន់ៗ និងចំណុចលម្អិតក្នុងអត្ថបទមកបំពេញ។ សិស្សអាចស្វែងរកបណ្ដុំព័ត៌មានដែលមានទំនាក់ទំនងគ្នាក្នុងរចនា-សម្ព័ន្ធអត្ថបទបានយ៉ាងងាយស្រួល និងអាចផ្សារភ្ជាប់ព័ត៌មានលម្អិតជាមួយនឹងគំនិតផ្សេងៗដើម្បីទាញរកសេចក្ដីសន្និដ្ឋាន។ សិស្សអាចប្រើប្រាស់តម្រុយ និងព័ត៌មានច្បាស់លាស់ងាយយល់ដើម្បីគាំទ្រសេចក្ដីសន្និដ្ឋាននៅពេលបំពេញព័ត៌មាន។ សិស្សក៏អាចកំណត់បានហេតុផលជាក់លាក់ភាគច្រើនសម្រាប់ពន្យល់ព្រឹត្តិការណ៍ណាមួយ និងប្រតិកម្មឆ្លើយតបរបស់តួអង្គក្នុងការរៀបរាប់ពីដំណើររឿងដែលព័ត៌មានទាំងនោះអាចប្រើបានចំពោះខ្លឹមសារក្នុងអត្ថបទតែប៉ុណ្ណោះ។ |
| **កម្រិត៥ (ពិន្ទុ ៣០៤ ដល់ក្រោម ៣១៧) ១៦%** | **ភ្ជាប់ព័ត៌មានដែលមានទំនាក់ទំនងគ្នាដើម្បីយល់ពីគំនិតសំខាន់ៗ** ក្នុងសមត្ថភាពទី៥នេះ សិស្សអាចផ្សារភ្ជាប់ទំនាក់ទំនងបណ្ដុំព័ត៌មានដែលទាក់ទងគ្នាក្នុងផ្នែកផ្សេងៗនៃអត្ថបទ ដូចជាតារាង និងដ្យាក្រាមជាដើម ដើម្បីស្វែងយល់គំនិតសំខាន់ៗ។ បរិបទ និងគំនិតក្នុងអត្ថបទដែលសិស្សបានជួប នឹងមិនងាយស្រួលសម្រាប់សិស្សទាំងស្រុងទេ។ សិស្សអាចស្គាល់ឃ្លា និងល្បះមួយចំនួនដែល មានអត្ថន័យដូចគ្នា ហើយធ្វើការសន្និដ្ឋានបែបសាមញ្ញ នៅពេលជួបព័ត៌មានពេញលេញខ្លះៗ។ សិស្សអាចកំណត់គោលបំណងពីលក្ខណៈពិសេសនៃអត្ថបទខ្លី និងសាមញ្ញ ហើយប្រើប្រាស់លក្ខណៈពិសេសនៃអត្ថបទទាំងនោះដើម្បីជួយរកព័ត៌មាន។ |
| **កម្រិត៣ (ពិន្ទុ ២៩៦ ដល់ក្រោម៣០៦) ១៤%** | **សរសេរនៅមានកម្រិតទាប គំនិតសាមញ្ញៗ មិនគ្រប់គ្រាន់ ប្រើប្រាស់វាក្យសព្ទនៅមានកម្រិត** ការសរសេររបស់សិស្សទាក់ទងនឹងបរិបទផ្ទាល់ខ្លួន និងតំបន់នៅមានកម្រិតទាប។ មានគំនិតសាមញ្ញខ្លាំងណាស់ មិនទាក់ទង និងមិនចប់។ គំនិតមិនជាប់ទាក់ទងគ្នាដែលធ្វើឱ្យអត្ថបទពិបាកយល់។ ឧទាហរណ៍ ក្នុងសំណេរអត្ថបទរឿងសាមញ្ញមួយអាចមានលំដាប់លំដោយខ្លះ តែមិនស្របគ្នា ឬមិនច្បាស់។ សិស្សអាចបង្ហាញពីការព្យាយាមសរសេរទម្រង់គួរសមខ្លះៗ និងអាចបង្កើតទម្រង់សំណួរបាន។ សិស្សអាចបង្កើតប្រយោគសាមញ្ញ ឬដដែលៗដែលប្រើសព្វនាម ឬនាមជាន់គ្នាដើម្បីភ្ជាប់គំនិតមួយទៅមួយទៀត។ សំណេររបស់សិស្សអាចអានបាន។ វាក្យសព្ទកម្រិតមូលដ្ឋានមិនគ្រប់គ្រាន់សម្រាប់ការពណ៌នាបានល្អ ឬពណ៌នាដដែលៗ។ |

| | |
|---|---|
| កម្រិត២(ពិន្ទុ ២៨៧ ដល់ក្រោម ២៩៦) ១៤% | **សរសេរនៅមានកម្រិតទាប គំនិតសាមញ្ញៗ គំនិតដោយផ្នែកៗ ប្រើប្រាស់វាក្យសព្ទមិនគ្រប់គ្រាន់**<br>ការសរសេររបស់សិស្សនៅកម្រិតនេះ នៅមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយ។ គំនិតអាចមិនច្បាស់ មិនទាក់ទង មានកម្រិត ឬគំនិតដោយផ្នែកៗប៉ុណ្ណោះ។ សិស្សអាចសរសេរប្រយោគត្រឹមត្រូវសាមញ្ញបានមួយ ឬប្រយោគដែលសរសេរមិនចប់មួយចំនួន ឬប្រយោគមានកំហុស និងប្រយោគប្រើសញ្ញាវណ្ណយុត្តិមិនត្រឹមត្រូវ។ សំណង់ប្រយោគសរសេរដដែលៗ។ វាក្យសព្ទកម្រិតមូលដ្ឋាន មិនគ្រប់គ្រាន់ឱ្យសិស្សពណ៌នាបានច្បាស់ ឬសរសេរដដែលៗ។ |
| កម្រិត១ ចុះ (ពិន្ទុតិចជាង ២៨៧)៥០% | **សមត្ថភាពមានកម្រិតទាបក្នុងការបង្ហាញគំនិតក្នុងសំណេរ**<br>សិស្សនៅកម្រិតនេះ សរសេរប្រយោគបានមួយចំនួនដែលខ្លឹមសារមានកម្រិត។ ឧទាហរណ៍ នៅពេលព្យាយាមពន្យល់រូបភាព សិស្សអាចផ្តោតលើលក្ខណៈដាច់ដោយឡែកមួយចំនួនប៉ុណ្ណោះ ឬពន្យល់ជាគំនិតទូទៅពេក។ សិស្សបង្កើតភាសាបង្គាប់បញ្ជាខ្លះៗ ប៉ុន្តែមិនជាប់ទាក់ទងគ្នា។ វាក្យស័ព្ទនៅមានកម្រិតក្នុងពន្យល់រូបភាព។ ប្រើពាក្យពេចន៍កម្រិតមូលដ្ឋាន និងដដែលៗ។ |
| កម្រិត៤ (ពិន្ទុ ២៨២ ដល់ក្រោម ២៩៥) ២៥% | **អនុវត្តលក្ខណៈចំនួន និងខ្នាតរង្វាស់រង្វាល់**<br>នៅកម្រិតទី៤ សិស្សអាចរកតម្លៃពាក់កណ្តាលនៃចំនួនគត់គូដែលមានលេខមួយខ្ទង់ និងយល់ច្បាស់ពីតម្លៃខ្ទង់នៃចំនួនទសភាគដែលមានផ្នែកទសភាគប្រាំខ្ទង់។ សិស្សអាចដោះស្រាយចំណោទទាក់ទងនឹងចំណុះដែលមិនត្រូវការប្តូរខ្នាត។ សិស្សអាចប្រើប្រាស់ចំណេះដឹងរបស់ពួកគេអំពីចំនួននាទីក្នុងមួយម៉ោង។ សិស្សអាចអានតម្លៃលេខលើក្រាបសសរ។ |
| កម្រិត៣ (ពិន្ទុ ២៦៩ ដល់ក្រោម ២៨២) ២០% | **យល់ច្បាស់ពីតម្លៃខ្ទង់ និងទំហំនៃរង្វាស់រង្វាល់**<br>សិស្សនៅកម្រិតទី៣ អាចរៀបលំដាប់ចំនួនគត់ដែលមានលេខពីរខ្ទង់។ សិស្សអាចអានតម្លៃប្រវែង និងរង្វាស់ម៉ាសលើឧបករណ៍រង្វាស់រង្វាល់ ដែលត្រូវការប៉ាន់ស្មានមួយចំនួន។ សិស្សអាចស្គាល់រូបធរណីមាត្រងាយៗ និងប្រៀបធៀបមុំ។ សិស្សអាចបកស្រាយក្រាបសសរងាយៗ។ |
| កម្រិត២ ចុះ (ពិន្ទុ២៦៩ ចុះ) ១៦% | មានសំណួរតេស្តតិចតួចសម្រាប់ពណ៌នាសមត្ថភាពសិស្សអាចដែលបំពេញបាននៅកម្រិតទាបជាងកម្រិតទី៣។ សិស្សមួយចំនួនគួរតែមានសមត្ថភាពធ្វើប្រមាណវិធីបូកចំនួនគត់ដែលមានលេខមួយខ្ទង់ និងចំនួនគត់ដែលមានលេខមួយខ្ទង់ ហើយសិស្សគួរតែមានសមត្ថភាពរាប់សំណុំនៃវត្ថុ ឬអាចស្គាល់ចំនួន។ |

## លទ្ធផលសិក្សាផ្នែកអំណាន សំណេរ និងគណិតវិទ្យា

- *ផ្នែកអំណាន សិស្សកម្ពុជាមានសមត្ថភាពប្រសើរជាងសិស្សមកពីប្រទេសឡាវ និងហ្វីលីពីន។*
- *ផ្នែកសំណេរសិស្សកម្ពុជាមានសមត្ថភាពប្រសើរជាងតែសិស្សមក*

ពីប្រទេសឡាវប៉ុណ្ណោះ។

- ផ្នែកគណិតវិទ្យាសិស្សកម្ពុជាមានសមត្ថភាពប្រសើរជាងសិស្ស មកពីប្រទេសឡាវ មីយ៉ាន់ម៉ា និងហ្វីលីពីន។
- សិស្ស មកពីប្រទេសឡាវមានកម្រិតសមត្ថភាពទាបជាងគេ និង វៀតណាមខ្ពស់ជាងគេ ក្នុងផ្នែកចំណេះដឹងទាំង៣។




## លទ្ធផលសិក្សាលើផ្នែកអំណាន តាមកម្រិតនីមួយៗ

- សិស្សមកពីប្រទេសឡាវមានសមត្ថភាពភាគរយកម្រិតទី២ ច្រើនជាងគេ (៥០%) និងទី៦ តែ២% ប៉ុណ្ណោះ
- សិស្ស វៀតណាម មានកម្រិតសមត្ថភាពទី២ តែ១% និងទី៦ ចំនួនច្រើនជាងគេ៨២%។




## លទ្ធផលសិក្សាលើផ្នែកអំណាន ធៀបនឹង SDG 4.1.1a

- វៀតណាមមានសិស្សដែលមានសមត្ថភាពអប្បបរមាបញ្ចប់បឋមសិក្សាកម្រិតទាប ស្របនឹង SDG 4.1.1 ផ្នែកអំណានស្ទើរទាំងអស់ (៩៩%) និងប្រទេសខ្ពស់ជាងគេបន្ទាប់គឺម៉ាឡេស៊ី (៩៥%)
- កម្ពុជា គឺ ៧៦% លើតែប្រទេសឡាវ និងហ្វីលីពីន ប៉ុណ្ណោះដែលសិស្សមានសមត្ថភាពបញ្ចប់បឋមសិក្សាកម្រិតទាប ស្របនឹង SDG 4.1.1។




## លទ្ធផលសិក្សាផ្នែកសំណេរ តាមកម្រិតនីមួយៗ

*សមត្ថភាពកម្រិត១ និង២ សិស្សថ្នាក់ទី៥ ប្រទេសកម្ពុជា និងឡាវ មានច្រើន ប្រហែលគ្នា (ប្រហែល៦០%) និងមានកម្រិត៧ និង៨ តិចស្មើគ្នា ២%។ ចំណែកម៉ាឡេស៊ី និងវៀតណាម មានកម្រិត១ និង២តិចជាងគេ ប្រហែល ១០% ប៉ុណ្ណោះ និងកម្រិត៧ និង៨ ច្រើនក្នុងនោះ វៀតណាម (៣២%) និង ម៉ាឡេស៊ី (១១%)។*




# លទ្ធផលសិក្សាលើផ្នែកគណិតវិទ្យា តាមកម្រិតនីមួយៗ



- នៅផ្នែកគណិតវិទ្យា មានតែប្រទេសវៀតណាម (៤២%) និង ម៉ាឡេស៊ី (៦%) ប៉ុណ្ណោះដែលសិស្សមានសមត្ថភាពដល់កម្រិតទី៩ៗ

**លទ្ធផលសិក្សារបស់សិស្ស ៖ ភេទ**




*នៅកម្ពុជា សិស្សស្រី ថ្នាក់ទី៥ រៀនបានលទ្ធផលល្អប្រសើរជាងសិស្សប្រុស គ្រប់មុខវិជ្ជាទាំងអស់ (អំណាន សំណេរ និងគណិតវិទ្យា)*

## ខ្លឹមសាររងនៃភាពជាពលរដ្ឋសកល

### *ឥរិយាបថ និងគុណតម្លៃ*

- *ការយល់ដឹងអំពីភាពជាពលរដ្ឋសកលនៅសាលារៀន* (Exposure to global citizenship issues at school)
- *ការព្រួយបារម្ភចំពោះបញ្ហាសកល* (Concern for global issues)
- *ការស្គាល់ខ្លួនឯងជាពលរដ្ឋនៅក្នុងទ្វីបអាស៊ី* (Asian identity)
- *ឥរិយាបថចំពោះការសិក្សាភាពជាពលរដ្ឋសកល* (Attitudes towards learning about global citizenship-related issues)

### *អាកប្បកិរិយា និងបំណិន*

- *អាកប្បកិរិយារំពឹងទុកនៃពលរដ្ឋល្អ* (Expected civic behavior)

- *អាកប្បកិរិយាឆ្លើយតបនឹងភាពជាពលរដ្ឋសកល* (Behavioral intentions associated with global citizenship)

## ការយល់ដឹងអំពីភាពជាពលរដ្ឋសកលនៅសាលារៀន




*សិស្សថ្នាក់ទី៩ នៅកម្ពុជាប្រហែលជា៣៨% ទៅ៦៩% លើកឡើងថា ពួកគេបានរៀន «ខ្លះ» ឬ «ច្រើន» អំពីប្រធានបទទាក់ទងនឹងភាពជាពលរដ្ឋសកលនៅសាលារៀន។*

## ការព្រួយបារម្ភចំពោះបញ្ហាសកល




## វិធានការកែលម្អអំណាន

*ការអនុវត្តវិធីសាស្ត្រអំណាន៖*

- *អភិវឌ្ឍឯកសារអំណានបន្ថែម និងផលិតសម្ភារៈឧបទេស*

- *អភិវឌ្ឍឯកសារវិធីសាស្ត្របង្រៀនអំណាន និងសំណេរឱ្យបាន គ្រប់គ្រាន់ និងសម្បូរបែប*
- *ជំរុញការប្រើប្រាស់កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងនៅតាម សាលាបឋមសិក្សាទូទាំងប្រទេសឱ្យបានប្រសិទ្ធភាព*
- *បំប៉នគ្រូពីវិធីសាស្ត្របង្រៀនអំណានតាមបរិបទថ្មី*
- *ពង្រីកកន្លែងអាន និងមធ្យោបាយអានឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព*
- *ពង្រឹងការវាយតម្លៃផ្នែកអំណាន និងសំណេរ*
- *បំប៉នសមត្ថភាពបណ្ណារក្ស ដើម្បីពង្រឹងសេវាអំណាន និងគ្រប់គ្រងឯកសារ*
- *បំផុស និងលើកកម្ពស់ការអានសម្រាប់អ្នកសិក្សា និងមហាជន គ្រប់វ័យ*

## **ផែនការកែលម្អការបង្រៀនវិទ្យាសាស្ត្រ**

*ការកែលម្អវិធីសាស្ត្របង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ៖*

- *អភិវឌ្ឍវិធីសាស្ត្របង្រៀនឱ្យស្របតាមការវិវត្តរបស់វិទ្យាសាស្ត្រ*
- *អនុវត្តវិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រតាមគោលវិធីស្វែម*
- *រៀបចំការបង្រៀនតាមបែបបញ្ញត្តិ* (Concept Based learning) *ឬ បង្រៀននិងរៀនតាមបែបរិះរក* (IBL) *ឬ អនុមានរួម* (Inductive Teaching)។
- *ផ្គត់ផ្គង់សម្ភារៈពិសោធន៍ និងបង្កើនបន្ទប់ពិសោធន៍សម្រាប់អនុវត្ត នៅតាមសាលារៀន*
- *បង្កើនការអនុវត្តជាក់ស្តែងការរៀន និងបង្រៀននៅក្នុងបន្ទប់ ពិសោធន៍ និងក្រៅថ្នាក់*
- *អភិវឌ្ឍសៀវភៅសិក្សាគោល ឯកសារជំនួយផ្សេងៗឱ្យទំនើប និង*

ទាន់សម័យ

- បំប៉នគ្រូពីវិធីសាស្ត្របង្រៀន និងការប្រតិបត្តិជាក់ស្តែង

## **ទិធានការកែលម្អការបង្រៀនគណិតវិទ្យា**

*ការកែលម្អវិធីសាស្ត្របង្រៀនមុខវិជ្ជាគណិតវិទ្យា ៖*

- *អភិវឌ្ឍវិធីសាស្ត្របង្រៀនឱ្យស្របតាមការវិវត្តរបស់វិទ្យាសាស្ត្រ*
- *អនុវត្តវិធីសាស្ត្របង្រៀនគណិតវិទ្យាតាមគោលវិធីស្នែម*
- *ពង្រឹងការរៀន និងបង្រៀនគណិតវិទ្យាថ្នាក់ដំបូង*
- *រៀបចំការបង្រៀនតាមបែបបញ្ញត្តិ* (Concept Based learning) *ឬបង្រៀននិងរៀនតាមបែបរិះរក* (IBL) *ឬ អនុមានរួម* (Inductive Teaching)
- *ផ្គត់ផ្គង់សម្ភារៈឧបទេសសម្រាប់បង្រៀននៅតាមសាលារៀន*
- *អភិវឌ្ឍសៀវភៅសិក្សាគោល សៀវភៅលំហាត់ និងឯកសារជំនួយផ្សេងៗឱ្យទំនើប និងទាន់សម័យ*
- *បំប៉នគ្រូពីវិធីសាស្ត្របង្រៀន និងការប្រតិបត្តិជាក់ស្តែង*

# ជំពូកទី ៣

# អធិការកិច្ចសាលារៀនតាមកាលកំណត់

## ៣.១. ប្រព័ន្ធអធិការកិច្ច




**អធិការកិច្ចសាលារៀន**

*ការដឹកនាំ និងគ្រប់គ្រង*

- *រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន និងបំណែងចែកភារកិច្ច ទទួលខុសត្រូវច្បាស់លាស់*
- *ប្រសិទ្ធភាព និងភាពស័ក្តិសមក្នុងការបែងចែកការងារ*
- *សម្ភារៈបរិក្ខារ និងសម្ភារៈឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀន*

និងរៀនមានប្រសិទ្ធភាព

- សុវត្ថិភាព និងបរិស្ថានល្អសម្រាប់ការរៀនសូត្រ និងអភិវឌ្ឍ

*ការបង្រៀន និងរៀន*

- ការបង្រៀន និងរៀនអនុវត្តតាមកម្មវិធីសិក្សា
- ការប្រើប្រាស់គរុកោសល្យ និងវិធីសាស្ត្រគ្រប់គ្រាន់ ពាក់ព័ន្ធនឹងគោលបំណងមេរៀន និងរៀន
- ការបង្រៀនស្របតាមតម្រូវការសិស្ស
- គ្រូបង្កើតបរិយាកាសលើកទឹកចិត្តឱ្យសិស្សខិតខំរៀនសូត្រ
- គ្រូកែលម្អការបង្រៀនរបស់ខ្លួន

## អភិបាលកិច្ចសាលារៀន

*លទ្ធផលសិក្សារបស់សិស្ស*

- លទ្ធសិក្សារបស់សិស្ស មានការរីកចម្រើនជាបន្តបន្ទាប់
- កម្មវិធីទាក់ទាញ ដើម្បីធានាឱ្យសិស្សមានវត្តមានក្នុងសាលារៀន
- ការវាយតម្លៃ និងការដាក់ពិន្ទុធ្វើឡើងប្រកបដោយសមធម៌ និងយុត្តិធម៌ និងតម្លាភាព

*តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន*

- តួនាទីរបស់សហគមន៍
- មាតាបិតា និងសិស្សចូលរួមក្នុងសហគមន៍

# ទំនាក់ទំនងរបស់អ្នកទទួលបន្ទុកក្នុងការពិនិត្យតាមដាន កម្រងសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ



# ជំពូកទី ៤

# វាយតម្លៃសិក្សា និងកំណែទម្រង់ការគ្រប់គ្រងសាលារៀន

## ៤.១. ការគ្រប់គ្រងតាមសាលារៀន

**ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាតាមសាលារៀន**

- *គ្របខ័ណ្ឌការងារសាលារៀនមានប្រសិទ្ធភាព*
- *ការអនុវត្តស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន*
- *ការគ្រោងថវិកា ការរៀបចំ និងការដាក់ស្នើគម្រោងថវិកា*

**ការគ្រប់គ្រងបុគ្គលិក**

- *វត្ថុបំណង និងដំណើការអនុវត្ត*
- *កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព*
- *ការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ*
- *ការវាយតម្លៃដំណើការអនុវត្តនៅដំណាច់ឆ្នាំ*
- *ការអភិវឌ្ឍវិជ្ជាជីវៈ ៖ ការបំប៉ននៅនឹងកន្លែង*

# ៤.២. អភិបាលកិច្ចសាលារៀន

## ការវាយតម្លៃសាលារៀន និងការវាយតម្លៃសិស្ស

- ប្រភេទ និងការវាយតម្លៃការអនុវត្ត
- ការប្រើប្រាស់លទ្ធផលវាយតម្លៃធ្វើឱ្យប្រសើរការអនុវត្តសាលារៀន
- ការវាយតម្លៃសិស្ស និងពេលវេលាវាយតម្លៃ
- ការប្រើលទ្ធផលតេស្តសិក្សា

## តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន

- តួនាទីរបស់សហគមន៍
- មាតាបិតា និងសិស្សចូលរួមក្នុងសហគមន៍

## គណនេយ្យភាពសាលារៀន

- ប្រភេទគណនេយ្យភាព
- ការវិភាគ ការអនុវត្តការងាររបស់សាលារៀន
- ការគ្រប់គ្រងហិរញ្ញវត្ថុ

## ការគ្រប់គ្រងសាលារៀន (SBM): 3 As






**ការវាយតម្លៃ**

- ការធ្វើតេស្តស្តង់ដាសិស្សដើមឆ្នាំ ប្រចាំខែ និងប្រចាំឆមាស
- ការធ្វើកិច្ចព្រមព្រៀង និងស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀននិងនាយកសាលា
- ការវាយតម្លៃផលសម្រេចសាលារៀនជាប់ស្តង់ដា

**ស្វ័យភាព**

- ការធ្វើផែនការកែលម្អថ្នាក់រៀន និងសាលារៀន
- ការបង្កើតគណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងសាលារៀន
- ការប្រជុំពិនិត្យតាមដានប្រចាំខែ និងត្រីមាស

**គណនេយ្យភាព**

- ការបិទផ្សាយលទ្ធផលតេស្តជាសាធារណៈ
- ការបិទផ្សាយស្វ័យ ការវាយតម្លៃប្រចាំឆ្នាំរបស់គ្រូបង្រៀន និងនាយកសាលា
- ការបិទផ្សាយចំណូលចំណាយរបស់ថ្នាក់រៀន និងសាលារៀន

**យុទ្ធសាស្ត្រអា៦**




## ៤.៣. អនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ

*១. ការធ្វើតេស្តស្តង់ដារវាស់សមត្ថភាពសិស្ស និងបិទផ្សាយលទ្ធផលជាសាធារណៈ នាំទៅបង្កើតការទាមទារពីអតិថិជននូវសេវាសាធារណៈនិងការបង្រៀនមានគុណភាព។*

*២. សហគមន៍ប្រើអំណាចសម្រេចចិត្តលើផែនការ ថវិកា និងកិច្ចការសាលារៀន នាំឱ្យសហគមន៍ជាម្ចាស់សាលារៀន និងជួយដល់សាលារៀន*

*៣. នាយកសាលាប្រើសិទ្ធិប្រតិបត្តិជានាកិច្ចការរដ្ឋបាលសាលារៀន និងបង្ហាញលទ្ធផលសិក្សា ចំណូលចំណាយ និងការរីកចម្រើនស្តង់ដាសាលារៀនជាសាធារណៈ ដែលនាំឱ្យសហគមន៍ជឿជាក់លើសាលារៀន នាយកសាលា និងគ្រូបង្រៀន។*

*៤. យកចិត្តទុកដាក់ថែរក្សាគ្រូបង្រៀន ទាំងសមត្ថភាពនិងជីវភាព ដែលជាគន្លឹះក្នុងការកសាងកិច្ចសន្យាសង្គមរវាងគ្រូបង្រៀន មាតាបិតាសិស្សនិងសិស្ស និងសហគមន៍ ហើយវានាំឱ្យមនុស្សទាំងអស់ធ្វើកិច្ចការរបស់ខ្លួនដើម្បីគាំទ្រការសិក្សារបស់សិស្ស។*

*៥. ការយកចិត្តទុកដាក់លើការអប់រំថែទាំកុមារតូច ជាកត្តាគន្លឹះនាំឱ្យកុមារមានសមត្ថភាពគ្រឹះ ដែលមានសមត្ថភាពទំនាក់ទំនង អាហារូបត្ថម្ភល្អ និងខួរក្បាលពេញលេញ អក្ខរកម្ម និងចិត្តសង្គម ហើយសមត្ថភាពទាំងនេះ*

*នឹងនាំឱ្យកុមារម្នាក់ៗក្លាយជាធនធានមនុស្សសំខាន់សម្រាប់អនាគត។*

*៦. **ការអនុវត្តវប្បធម៌** គឺនាំឱ្យបុគ្គលិកសាលាទាំងអស់គោរពគ្នា ដោយប្រើអំណាចសម្រាប់ធ្វើតែកិច្ចការត្រូវធ្វើ មិនប្រើអំណាចខុសគោលដៅ ឬប្រើសម្បត្តិសាលាសម្រាប់ប្រយោជន៍បុគ្គល និងការអនុវត្តគុណតម្លៃជាកត្តានាំឱ្យមនុស្សម្នាក់ៗក្លាយជាមនុស្សល្អ ដោយសារមនុស្សម្នាក់ៗ ធ្វើតែអ្វីដែលត្រូវ និងជួយមនុស្សទាំងអស់ក្នុងសហគមន៍។*

## រៀបចំផែនការកែលម្អសាលារៀន




## បង្កើតវប្បធម៌ជួយសិស្សតាមរយៈតេស្ត



## ៤.៤. បង្កើតវប្បធម៌ជួយសិស្សតាមរយៈតេស្ត

- បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់
- កិច្ចតែងការបង្រៀនតាមមេរៀន និងតាមកម្រិតថ្នាក់ (ផ-សម្រេច) (Ins:បណ្ណាសង្កើតថ្នាក់ )
- តេស្តល្បឿនអំណានភាសាខ្មែរថ្នាក់ទី៩ (២០០ពាក្យ/នាទី)
- តេស្តគ្រប់មុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម អក្សរសិល្ប៍ បច្ចេកវិទ្យាព័ត៌មាន
- លទ្ធផលប្រឡងឆមាសគ្រប់មុខវិជ្ជាគ្រប់កម្រិតថ្នាក់ (ជាប់-ធ្លាក់)
- តេស្តប្រឡងឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ (K,M,S)
- ការជួបជាមួយមាតាបិតា និងសិស្សប្រចាំត្រីមាស (៣ត្រីមាស)
- ចំនួនម៉ោងសិក្សាជាមធ្យមតាមមុខវិជ្ជា (ឆ១. ឆ២) ៖
    - ម៉ោងសិក្សាត្រូវអនុវត្ត ម៉ោងសិក្សាបានអនុវត្ត
    - ម៉ោងសិក្សាដែលសាលាបិទទ្វារខុសប្រតិទិនសិក្សា ម៉ោងសិក្សាដែលគ្រូអវត្តមាន
- ចំនួនសិស្សអវត្តមាន «ពី៥ដង-២០ដង» (ត្រីមាស១-២-៣)
- កិច្ចការផ្ទះគ្រប់មុខវិជ្ជាដាក់ឱ្យសិស្ស និងមានការកែពីគ្រូ «ជាលំហាត់-គម្រោង» (បានដាក់-បានកែនិងផ្តល់យោបល់)
- ការសិក្សាស្រាវជ្រាវមេរៀនដោយក្រុមមុខវិជ្ជា (ផ-ស)

- លទ្ធផលពីការធ្វើតេស្តអាចឱ្យគ្រូ និងនាយកសាលារិះរកវិធានការជួយសិស្សរៀនយឺត និងរៀនលឿនជាបន្ទាន់ ដោយមិនទុកឱ្យសិស្សជួបការលំបាក និងរៀនមិនចេះទៅតាមកម្រិតស្តង់ដាលទ្ធផលសិក្សានៃមេរៀននីមួយនៅក្នុងខែនោះទេ។
- ផ្តល់ព័ត៌មានដល់មាតាបិតាពីលទ្ធផលតេស្ត និងពិភាក្សាពីការជួយសិស្ស។
- ធ្វើបែបនេះជាការលើកទឹកចិត្តសិស្ស និងគ្រូបង្រៀនឱ្យខិតខំ

និងយកចិត្តទុកដាក់ក្នុងការរៀន និងបង្រៀន និងបង្កើនការជឿទុកចិត្តរបស់មាតាបិតាសិស្ស និងសហគមន៍។

- ការធ្វើតេស្តពល់ចុងខែ គឺជាការអនុវត្តប្រព័ន្ធពិនិត្យតាមដានសម្រាប់សាលារៀនគោលដៅថ្មី ការធ្វើតេស្តនៅដើមខែដំបូងនៃឆ្នាំសិក្សា គឺវាជាការធ្វើរោគវិនិច្ឆ័យកម្រិតសមត្ថភាពសិក្សារបស់សិស្សម្នាក់ៗ តាមមេរៀននៃមុខវិជ្ជានីមួយៗ។ លទ្ធផលតេស្តត្រូវប្រើសម្រាប់ធ្វើផែនការបង្រៀន៣ខែដំបូងជួយសិស្សរៀនយឺត និងផ្តោតការបង្រៀនជួយសិស្សរៀនយឺតនៅក្នុងខែដំបូង។ សម្រាប់សាលាគោលដៅចាស់ លទ្ធផលតេស្តនៅចុងឆ្នាំនៃឆ្នាំសិក្សាមុនអាចយកមកប្រើបានសម្រាប់ធ្វើផែនការបង្រៀន៣ខែដំបូងជួយសិស្សរៀនយឺត និងផ្តោតការបង្រៀនជួយសិស្សរៀនយឺតនៅក្នុងខែដំបូង។
- ពិនិត្យតាមដានលទ្ធផលសិក្សាសិស្សប្រចាំខែ សម្រាប់សិស្សម្នាក់ៗ សមត្ថភាពសិស្សកម្រិតថ្នាក់រៀន និងកម្រិតសាលារៀន។ លទ្ធផលតេស្តគឺសម្រាប់យកទៅប្រើប្រាស់ ក្នុងការកែលម្អការបង្រៀននៅខែបន្ទាប់។ លទ្ធផលតេស្តនៅចុងត្រីមាស នឹងត្រូវយកទៅប្រើប្រាស់សម្រាប់ធ្វើផែនការបង្រៀននៅត្រីមាសបន្ទាប់។
- ការធ្វើតេស្តនៅចុងឆមាសគឺជា ការអនុវត្តប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សាសិស្សប្រចាំឆមាស នៅកម្រិតសាលារៀន សម្រាប់យកទៅធ្វើផែនការបង្រៀននៅត្រីមាសទី៣ និងផ្តោតការបង្រៀនជួយសិស្សរៀនយឺតនៅក្នុងខែបន្ទាប់ ដើម្បីឈានទៅសម្រេចបានក្រុមគោលដៅប្រចាំឆ្នាំ និងប្រៀបធៀបជាមួយលទ្ធផលសិក្សារបស់សិស្សកម្រិត (ការិយាល័យអប់រំ) មន្ទីរអប់រំ និងក្រសួងអប់រំ ផ្អែកលើកម្មវិធីសិក្សាលម្អិត។ ការធ្វើតេស្តនៅចុងឆមាស គឺជាការធ្វើតេស្តចុងខែនៃឆមាសផង រួមជាមួយសំណួរតេស្តឆមាសផង។
- ការធ្វើតេស្តស្តង់ដាគឺជាតេស្តដែលអាចជឿទុកចិត្តបាន ដោយសារ

ការធ្វើតេស្តមានលក្ខខណ្ឌពីរគឺ ១) សំណួរតេស្ត គឺផលិតឡើង ដោយក្រុមគ្រូនៃមុខវិជ្ជា និងសំណួរតេស្តត្រូវបានជ្រើសរើសដោយ ក្រុមបច្ចេកទេសរបស់សាលារៀន និង ២) ការធ្វើតេស្តគឺនៅក្រោម ការដឹកនាំ និងគ្រប់គ្រងផ្ទាល់របស់នាយកសាលារៀន និងក្រុម បច្ចេកទេស មានការចូលរួមពីគណៈកម្មការគ្រប់គ្រងសាលារៀន និងសហគមន៍។

## ៤.៥. សកម្មភាពសព្វគ្រប់នៃការធ្វើតេស្តស្តង់ដារវាយតម្លៃសមត្ថភាពសិស្ស

១. ប្រជុំអំពីការធ្វើតេស្តស្តង់ដារវាយតម្លៃសមត្ថភាពសិស្ស ជាមួយ មាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន គ្រូបង្រៀន និងនាយក សាលា។

២. បង្ហាញនូវប្រភេទសំណួរតេស្ត និងរបៀបនៃការរៀបចំសំណួរតេស្ត។

៣. រៀបចំគណៈកម្មការបច្ចេកទេសគ្រប់គ្រងតេស្តសមត្ថភាពសិស្ស និងពិភាក្សាអំពីរបៀបអនុវត្តតេស្ត និងរៀបចំសន្លឹកកិច្ចការតេស្ត។

៤. អនុវត្តជាក់ស្តែងនូវការធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្ស។

៥. កែកិច្ចការតេស្ត បញ្ចូលទិន្នន័យក្នុងប្រព័ន្ធ គណនាកម្រិត សមត្ថភាពសិស្ស និងពិភាក្សាអំពីការផ្សព្វផ្សាយជាសាធារណៈ។

៦. ប្រជុំជាមួយមាតាបិតា សិស្ស សហគមន៍ ដើម្បីផ្តល់ព័ត៌មានអំពី លទ្ធផលតេស្ត និងពិភាក្សាថាភាគីពាក់ព័ន្ធត្រូវធ្វើអ្វីខ្លះជួយសិស្ស។

៧. បិទផ្សាយជាសាធារណៈនូវលទ្ធផលតេស្តនៅទីធ្លាសាលារៀន។

៨. ប្រជុំអំពីការកែលម្អការបង្រៀន ដោយប្រើលទ្ធផលតេស្តស្តង់ដា ពិសេសរៀបចំផែនការបង្រៀនបីខែ ផ្តោតលើការជួយសិស្ស បំពេញគម្លាតសមត្ថភាព។

៩. រៀបចំថ្នាក់រៀនពិសេស ថ្នាក់ជួយសិស្សដែលរៀនយឺតខ្លាំង និង

*មធ្យម និងអនុវត្តបង្ហាញនូវវិធីសាស្ត្របង្រៀនដែលប្រាកដជួយសិស្សបាន។*

### ផែនការបង្រៀនដោយប្រើលទ្ធផលពីការធ្វើតេស្តស្តង់ដាចំនួន និងភាគរយក្រុមគោលដៅតាមកម្រិតសមត្ថភាព និងតាមត្រីមាស ភាសាខ្មែរ

| សិស្សថ្នាក់ទី៧ | មូលដ្ឋាន | | ត្រីមាស១ | | ត្រីមាស២ | | ត្រីមាស៣ | | ត្រីមាស៤ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| សិស្សធ្លាក់ E | | | | ៣០ | | ២០ | | ១០ | | ០ |
| សិស្សជាប់មធ្យម D | | | | ២០ | | ១៥ | | ១០ | | ០ |
| សិស្សជាប់ល្អបង្គួរ C | | | | ២០ | | ២៥ | | ២៥ | | ២០ |
| សិស្សជាប់ល្អ B | | | | ២០ | | ២៥ | | ៣៥ | | ៥០ |
| សិស្សជាប់ល្អប្រសើរ A | | | | ១០ | | ១៥ | | ២០ | | ៣០ |
| សិស្សសរុប | | | | ១០០ | | ១០០ | | ១០០ | | ១០០ |

## ៤.៦. ការលើកទឹកចិត្តសិស្សរៀនយឺត និងការប្រជុំជាមួយមាតាបិតាប្រចាំខែ

- *គ្រូគ្រប់មុខវិជ្ជាជួបផ្ទាល់ជាមួយសិស្សរៀនយឺតជាងគេបំផុតម្នាក់ម្តងៗ ដើម្បីធ្វើសតិអារម្មណ៍ និងលើកទឹកចិត្តឱ្យសិស្សខំរៀន និងគ្រូបង្ហាញការប្តេជ្ញាចិត្តជួយសិស្សរៀនយឺត។*
- *គ្រូគ្រប់មុខវិជ្ជាជួបជាមួយមាតាបិតាសិស្សរៀនយឺតម្នាក់ម្តងៗ នៅសាលារៀន ឬនៅផ្ទះគាត់ ដើម្បីលើកទឹកចិត្តគាត់ឱ្យសហការ*

ជាមួយគ្រូ ដើម្បីជួយកូនគាត់។

- នាយកសាលាសហការជាមួយគ្រូប្រចាំថ្នាក់ ធ្វើលិខិតអញ្ជើញជាផ្លូវការ ទៅមាតាបិតាសិស្សរៀនលឿន មកសាលារៀន ដើម្បីលើកសរសើរដល់គាត់ ដែលបានជួយកូនរៀនពូកែ។ បើអាចធ្វើទៅបាន សាលារៀនប្រគល់លិខិតថ្លែងអំណរគុណជូនគាត់។
- នាយកសាលា ដឹកនាំជាគំរូការប្រជុំប្រចាំខែរបស់គ្រូប្រចាំថ្នាក់ និងគ្រូមុខវិជ្ជា ជាមួយមាតាបិតាសិស្សក្នុងថ្នាក់ (ជាពិសេសមាតាបិតាសិស្សរៀនយឺត) ដើម្បីរាយការណ៍ពីលទ្ធផលតេស្តប្រចាំខែ និងការរិះរកវិធានការរួមគ្នា ជួយសិស្សរៀនយឺត និងរៀនលឿនបន្ថែមទៀត។
- នាយកសាលា ប្រជុំជាមួយគ្រូបង្រៀនរៀបចំផែនការបង្រៀន៣ខែ ដោយកំណត់ក្រុមគោលដៅជួយសិស្សរៀនយឺត។
- នាយកសាលារាយការណ៍ប្រចាំខែទៅការិយាល័យអប់រំ និងមន្ទីរអប់រំ អំពីលទ្ធផលសិក្សារបស់សិស្សគ្រប់ថ្នាក់ និងគ្រប់មុខវិជ្ជា។

# ជំពូកទី ៥

# ការសិក្សា និងរង្វាយតម្លៃ ក្នុងសតវត្សទី២១

## ៥.១. កំណែទម្រង់រង្វាយតម្លៃសិក្សារបស់សិស្ស

*ដូចបានចង្អុលបង្ហាញនៅជំពូកទី១រួចហើយថារង្វាយតម្លៃសិក្សាក្នុងសតវត្សទី២១នេះមិនមែនពឹងផ្អែកតែលើរង្វាយតម្លៃតាមដំណាក់កាលឬរង្វាយតម្លៃបែបសរុបតែម្យ៉ាងនោះទេ។ ដើម្បីបណ្តុះបណ្តាលសិស្សប្រកបដោយប្រសិទ្ធភាពនិងត្រៀមលក្ខណៈប្រកួតប្រជែងទាំងក្នុងកម្រិតតំបន់និងអន្តរជាតិ ព្រមទាំងប្រែក្លាយទៅជាពលរដ្ឋសកល ការសិក្សានិងរង្វាយតម្លៃសិក្សាតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ។ សិស្សត្រូវមានគំនិតផ្តួចផ្តើម និងរៀនឱ្យលើសពីក្នុងសៀវភៅ ចំណែកអាណាព្យាបាលត្រូវតាមដាននិងសហការជាមួយសាលាតាមរយៈការចូលរួមប្រជុំពិភាក្សារកដំណោះស្រាយបញ្ហាផ្សេងៗដែលជាឧបសគ្គក្នុងការសិក្សា ហើយគ្រូបង្រៀនត្រូវបត់បែនកិច្ចតែងការទៅតាមកម្រិតយល់ដឹង និងសមត្ថភាពចាប់បានរបស់សិស្សម្នាក់ៗ។ ក្នុងន័យនេះ នាយកសាលាមានតួនាទីមិនអាចខ្វះបានក្នុងការសម្របសម្រួល និងចូលរួមអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យទទួលបានលទ្ធផលខ្ពស់។*

*ភាពជាអ្នកដឹកនាំរង្វាយតម្លៃរបស់នាយកមានចំណុចរួមដូចតទៅ* (H.Y. Tan and K. Tan in Wong, Hairon, and Ng, eds, 2019) ៖

***ទីមួយ***-*នាយកមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ កម្រិតសាលារៀន ជាពិសេសការធ្វើកំណែទម្រង់វង្វាយតម្លៃ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។ ជាការពិតសិស្សានុសិស្ស និងមាតាបិតាយកចិត្តទុកដាក់លើលទ្ធផលនៃការប្រឡង ជាពិសេស ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការទទួលបាននិទ្ទេស A ក្នុងការប្រឡង។ ក៏ប៉ុន្តែវិធីសាស្ត្របង្រៀនបែបថ្មី ដែលផ្តោតលើបំណិនសតវត្សរ៍ទី២១ មិនអាចវាស់វែងបាន តាមរយៈការប្រឡងបានឡើយ។ មានតែគ្រូប្រចាំថ្នាក់ទេ ដែលអាចធ្វើការវាយតម្លៃជាប្រចាំ ដោយផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្ស។*

***ទីពីរ***-*វង្វាយតម្លៃមិនអាចបំបែកការសិក្សារៀនសូត្រ ដែលមានចរិតទូលំទូលាយ និងប្រទាក់ក្រឡាគ្នា។ ដូចនេះ វង្វាយតម្លៃត្រូវតែមានសង្គតិភាព និងប្រទាក់ក្រឡា។ ក្នុងន័យនេះ នាយកត្រូវមានគោលការណ៍ដូចតទៅ ៖ (១) គ្រូត្រូវរៀបចំក្របខ័ណ្ឌវង្វាយតម្លៃឱ្យមានសង្គតិភាព ដើម្បីសម្រួលដល់ការរៀនរបស់សិស្សឱ្យប្រទាក់ក្រឡា និងទូលំទូលាយ (២) គំនិតបន្ថែមទៀតរបស់គ្រូក្នុងការវាយតម្លៃត្រូវបញ្ចូលក្នុងក្របខ័ណ្ឌរួម។*

***ទីបី***-*ភាពជាអ្នកដឹកនាំវង្វាយតម្លៃ គឺជាលក្ខខណ្ឌមិនអាចខ្វះបានក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ និងការលើកកម្ពស់តម្លៃនៃការអប់រំ។ សាលាត្រូវមានទស្សនវិស័យច្បាស់លាស់ ដើម្បីធានាថាវង្វាយតម្លៃដែលមានលក្ខណៈទូលំទូលាយ និងប្រទាក់ក្រឡាចូលរួមក្នុងការសម្រេចបាននូវទស្សនវិស័យនេះ។*

***ទីបួន***-*ភាពជាអ្នកដឹកនាំវង្វាយតម្លៃត្រូវត្រៀមលក្ខណៈដោះស្រាយបញ្ហា ដែលគ្រូអាចមានការលំបាក ក្នុងផ្លាស់ប្តូរវិធីវង្វាយតម្លៃពីការប្រឡងទៅវង្វាយតម្លៃសិស្សតាមវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលមានលក្ខណៈស្មុគស្មាញ។*

# ការកែលម្អវិធីសាស្ត្របង្រៀន
# នៅសាលារៀនជំនាន់ថ្មី (NGS)

| សមាសភាគអប់រំ | សតវត្សទី២០ | សតវត្សទី២១ |
|---|---|---|
| ▪ ទស្សនាទានអប់រំ | ▪ ការផ្ទេរព័ត៌មាន<br>▪ ការសិក្សាអកម្ម<br>▪ ការទន្ទេញចាំមាត់ | ▪ រៀនដើម្បីចេះរៀន<br>▪ ការសិក្សាសកម្ម<br>▪ ការសិក្សាផ្តោតលើបញ្ញត្តិ |
| ▪ កម្មវិធីសិក្សា | ▪ ស្តង់ដា<br>▪ ផ្តោតលើសៀវភៅ | ▪ ជាបុគ្គល<br>▪ ផ្តោតលើបញ្ញត្តិ<br>▪ ការស្រាវជ្រាវ<br>▪ រៀនលើសពីសៀវភៅ |
| ▪ វង្វាយតម្លៃសិក្សា | ▪ ផ្តោតលើការធ្វើតេស្ត | ▪ ផ្តោតលើសមត្ថភាព |
| ▪ ការរៀបចំថ្នាក់រៀន | ▪ ស្តង់ដា<br>▪ សិស្សអង្គុយជាជួរ | ▪ ការរៀបចំតុកៅអីទៅតាមវិធីសាស្ត្របង្រៀន<br>▪ រៀបចំដើម្បីរៀនជាក្រុម |
| ▪ ការរៀបចំសាលារៀន | ▪ ទៅតាមរចនាសម្ព័ន្ធរដ្ឋបាល | ▪ រៀបចំតាមបណ្តាញ និងទំនាក់ទំនង |
| ▪ ទស្សនវិជ្ជាអប់រំ | ▪ អនុវត្តតាមការណែនាំ<br>▪ គោរពបទបញ្ជា<br>▪ មានឯកភាព | ▪ ការសិក្សាមានលក្ខណៈរស់រវើក<br>▪ ការសិក្សាដោយបត់បែន<br>▪ នវានុវត្តន៍ |
| ▪ ស្ថាបត្យកម្មសាលារៀន | ▪ ឯកសណ្ឋាន<br>▪ ស្តង់ដា | ▪ មានភាពរស់រវើក<br>▪ គ្មានស្តង់ដា |

## ក្របខ័ណ្ឌបង្រៀនស្ថាបនានិយម

| ទស្សនវិជ្ជា | វិធីសាស្ត្រ | បច្ចេកទេស |
|---|---|---|
| **ស្ថាបនានិយម**<br>គឺជាវិធីសាស្ត្រ ដែលតម្រូវឱ្យគ្រូ និងសិស្សត្រូវស្ថាបនា ឬស្វែងរកចំណេះដឹងដោយខ្លួនឯង ដោយផ្ដោតលើបទពិសោធរបស់អ្នកសិក្សា | **វិធីសាស្ត្រគម្រោង** | ▪ ការកំណត់គម្រោង<br>▪ សិស្សរៀនជាក្រុម<br>▪ សិស្សស្រាវជ្រាវ<br>▪ សិស្សធ្វើបទបង្ហាញ |
| | **វិធីសាស្ត្ររៀនតាមបែបរិះរក** | ▪ សិស្សកំណត់បញ្ហាដែលគេចង់រិះរក<br>▪ សិស្សស្រាវជ្រាវ<br>▪ សិស្សធ្វើបទបង្ហាញ<br>▪ សិស្សស្រាវជ្រាវ<br>▪ សិស្សឆ្លុះបញ្ចាំងពីដំណើរការដែលទទួលលទ្ធផល និងមិនទទួលលទ្ធផល |
| | **វិធីសាស្ត្ររៀនតាមបែបរិះរក** | ▪ ជំហានទី១ ៖ ឈ្វេងយល់ពីមេរៀន និងកំណត់បញ្ហា<br>▪ ជំហានទី២ ៖ សិស្សលើកឡើងពីអ្វីដែលខ្លួនដឹង<br>▪ ជំហានទី៣ ៖ សិស្សកំណត់ពីបញ្ហា<br>▪ ជំហានទី៤ ៖ សិស្សស្រាវជ្រាវចំណេះដឹង<br>▪ ជំហានទី៥ ៖ សិស្សរកដំណោះស្រាយ<br>▪ ជំហានទី៦ ៖ សិស្សធ្វើបទបង្ហាញ និងគាំទ្រដំណោះស្រាយ<br>▪ ជំហានទី៧ ៖ សិស្សពិនិត្យសមិទ្ធផល |

## ការសិក្សាបែបគម្រោង

- *ក្នុងឆ្នាំ ២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តការសិក្សាបែបគម្រោង។*

*គោលបំណង ៖*

- *ការបង្រៀនមានប្រសិទ្ធភាព ដោយឱ្យសិស្សអនុវត្តការសិក្សាបែបគម្រោង តាមប្រធានបទពាក់ព័ន្ធ ដើម្បីបង្កើតនូវផលិតផលខិតបណ្ណ កម្រងរូបភាព ថតសំឡេង បទបង្ហាញ ក្រាហ្វិក*

របាយការណ៍ ចងក្រងឯកសារ។ល។ ហើយសមិទ្ធផលត្រូវបានធ្វើបទបង្ហាញដល់អ្នកពាក់ព័ន្ធ។

- សមត្ថភាពសំខាន់ៗដែលសិក្ខាកាមទទួលបាន ៖

១. ទស្សនៈថ្មីនៃការសិក្សារបស់សិស្ស និងការរៀនពិតប្រាកដ

២. របៀបចំផែនការអនុវត្ត «ការសិក្សាបែបគម្រោង» និងការវាយតម្លៃការសិក្សារបស់សិស្ស

៣. ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួន

៤. ការបង្ហាញសមិទ្ធផលនៃការអនុវត្តគម្រោងដល់អ្នកពាក់ព័ន្ធ និង

៥. ការប្រើប្រាស់ឧបករណ៍ ICT ក្នុងការបង្រៀន និងរៀនដែលជំរុញឱ្យមានការសិក្សាដោយឯករាជ្យ (កុំព្យូទ័រ ថាប់ប្លែត។ល។)។

## ៥.២. ការសិក្សាបែបគម្រោង

**លទ្ធផលរំពឹងទុក ៖**

ចំពោះគ្រូបង្រៀន ៖

- មានផែនការការងារគម្រោងនិងក្លឹបមុខវិជ្ជា
- អនុវត្តការងារគម្រោងនិងក្លឹបមុខវិជ្ជារបស់ខ្លួន
- អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនលើបច្ចេកទេសបង្រៀន
- មានបំណិនក្នុងការប្រើប្រាស់ឧបករណ៍ ICT ដែលមានស្រាប់ក្នុងសាលារៀនរបស់ខ្លួន។

ចំពោះសិស្ស ៖

- សប្បាយរីករាយក្នុងការសិក្សានិងទទួលបានការសិក្សាពិតប្រាកដ
- មានជំនាញសិក្សាស្រាវជ្រាវ និងធ្វើបទបង្ហាញ
- អភិវឌ្ឍបំណិនទូទៅ និងមានឥរិយាបថសមស្រប
- អនុវត្តការប្រើប្រាស់ឧបករណ៍ ICT។

កត្តាដែលនាំឱ្យមានការរៀនពិប្រាកដ ៖

- ការឆ្លុះបញ្ចាំងពីការរៀន
- សំណួររិះរកនិងស្វែងយល់បន្ថែម
- សំណួរដែលមានការគិតកម្រិតខ្ពស់
- ការរៀនពីដំណោះស្រាយបញ្ហា
- ការរៀនជាបណ្ដាញនិងជាលំនាំអេកូឡូស៊ី ៖ ការភ្ជាប់គំនិតផ្ទាល់ខ្លួននិងបទពិសោធន៍របស់បុគ្គលម្នាក់ៗ ទាក់ទងទៅនឹងការពង្រីក ការកែប្រែរចនាសម្ព័ន្ធនិងការផ្លាស់ប្ដូរគំនិតចាស់ តាមរយៈការទំនាក់ទំនងជាមួយអ្នកដទៃ។

***លទ្ធផលសិក្សា*** ៖ តាមរយៈការសិក្សាបែបគម្រោង លទ្ធផលសិក្សា គឺការអនុវត្ត ចំណេះដឹង ការប្រាស្រ័យទាក់ទង កិច្ចសហការ ភាពច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា និងការរៀនដោយម្ចាស់ការ ការធ្វើការជាក្រុម ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ការធ្វើអន្តរកម្មរវាងផ្នែក ឬមុខវិជ្ជាជាច្រើនមិនមែនផ្ដោតលើតែផ្នែកមួយ ឬមុខវិជ្ជាមួយឡើយ។

*ប្រភេទនៃការសិក្សាបែបគម្រោង*

*ប្រធានបទអាចជា ៖*

- ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ (ប្រាសាទដែលមានក្នុងមូលដ្ឋាន ទីកន្លែងប្រវត្តិសាស្ត្រ ឈ្មោះភូមិឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...) អាចធ្វើជាក្លឹបមុខវិជ្ជា។
- វប្បធម៌ស ប្រពៃណី (របាំ សិល្បៈ បុណ្យទាន ឬក៏ដកស្រង់ប្រធានបទ ក្នុងកម្មវិធីសិក្សា...)។
- របកគំហើញវិទ្យាសាស្ត្រ (និយាយអំពីកព និយាយអំពីការវិវឌ្ឍ មនុស្ស សត្វ ជំងឺ ប្រព័ន្ធគ្រោងឆ្អឹងមនុស្ស សូរ្យគ្រាស ឬក៏ដកស្រង់ប្រធានបទក្នុងកម្មវិធីសិក្សា...)
- រៀបចំពិសោធន៍វិទ្យាសាស្ត្រ (គីមីវិទ្យា រូបវិទ្យា...) អាចធ្វើជាក្លឹបមុខវិជ្ជា។

- *មេរៀនតាមមុខវិជ្ជាដែលមាននៅក្នុងកម្មវិធីសិក្សា (ភាសារខ្មែរ/អង់គ្លេស ៖ អានអត្ថបទដោយប្រើល្បឿនបានត្រឹមត្រូវ ការពន្យល់ពាក្យពិបាក ការរកវេវចនសព្ទ...) អាចធ្វើជាក្វីបមុខវិជ្ជា។*

## ៥.៣. វិធីសាស្ត្រវាយតម្លៃសិក្សានៅសាលារៀនជំនាន់ថ្មី (NGS) «គោលនយោបាយវាយតម្លៃសិស្ស»

*តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការខេប (KAPE) សាលារៀនជំនាន់ថ្មីបានដាក់ចេញនៅក្នុងខែមករា ឆ្នាំ ២០២៣ នូវ «គោលនយោបាយវាយតម្លៃសិស្ស» ក្នុងគោលដៅលើកកម្ពស់ការអនុវត្តនូវវិធីសាស្ត្របង្រៀនសម្រាប់សតវត្សទី២១ ដែលតម្រូវឱ្យសិស្សសិក្សានៅក្នុងបន្ទប់ពិសោធ ធ្វើការស្រាវជ្រាវ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឌីជីថល។*

*«គោលនយោបាយវាយតម្លៃសិស្ស» កាត់បន្ថយការផ្តោតខ្លាំងពេកលើការប្រឡង និងការសិក្សាដើម្បីធ្វើតេស្ត ដើម្បីបង្កើតនូវវប្បធម៌សិក្សាថ្មីដែលផ្តោតលើសមត្ថភាពពេញលេញរបស់សិស្ស ដែលត្រូវមាននូវ ៖ (១) វិជ្ជាសម្បទា (២) បំណិនសម្បទា (៣) ចរិយាសម្បទា រួមទាំងសីលធម៌ សុជីវធម៌ជាពលរដ្ឋល្អ និងជាពលរដ្ឋសាកលល្អ។*

### គោលការណ៍នៃវាយតម្លៃ

***គោលការណ៍ទី១*** *៖ ប្រើវិធីសាស្ត្រវាយតម្លៃសម្បូណ៌បែប ៖ តុល្យភាពរវាងការវាយតម្លៃតាមដំណាក់កាល និងការវាយតម្លៃសរុប និងប្រើប្រាស់បច្ចេកទេសផ្សេងៗ (សំណួរបើក សំណួរបិទ ការសរសេរតែងសេចក្តី ការសិក្សាគម្រោង ។ល។)។*

***គោលការណ៍ទី២*** *៖ សារសំខាន់នៃកំហុស ដែលផ្តល់ឱកាសសម្រាប់ការកែលម្អ។*

*គោលការណ៍ទី៣ ៖ តួនាទីនៃមតិយោបល់ត្រឡប់ស្ថាបនា ដោយគ្រូត្រូវផ្តល់យោបល់ត្រឡប់ ដើម្បីលើកទឹកចិត្តសិស្សឱ្យប្រឹងរៀន។*

*គោលការណ៍ទី៤ ៖ រង្វាយតម្លៃជាមធ្យោបាយ មិនមែនគោលដៅទេ។ គ្រូត្រូវប្រើប្រាស់រង្វាយតម្លៃ ដើម្បីកែលម្អ។*

*គោលការណ៍ទី៥ ៖ កាត់បន្ថយការប្រៀបធៀបរវាងសិស្ស និងការប្រណាំងប្រជែងខ្លាំង ដើម្បីចៀសវាងការបាក់ទឹកចិត្ត និងការធ្វើចំណាត់ថ្នាក់សិស្ស។*

## ការដាក់ពិន្ទុ

*ការដាក់ពិន្ទុត្រូវប្រើប្រាស់រង្វាស់ពី១ ដល់១០ ដែលពិន្ទុ ៥ គឺការកំណត់ជាប់ ឬធ្លាក់ ហើយគ្រូមិនត្រូវប្រើប្រាស់ខ្លាំងពេកនូវការធ្វើចំណាត់ថ្នាក់សិស្ស។*

*ការកំណត់លក្ខណៈវិនិច្ឆ័យ* (Rubrics) *៖ គ្រូត្រូវរៀបចំតារាងរង្វាយតម្លៃ ដោយពិនិត្យលើបំណិនផ្សេងៗរបស់សិស្ស ៖ ដូចជាការតស៊ូមតិ ការពិភាក្សា ការធ្វើបទបង្ហាញ ការបង្កើតថ្មី ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា។ល។*

*ភាពទន់ភ្លន់ក្នុងការដាក់ពិន្ទុ ៖ គ្រូត្រូវផ្តោតលើការលើកទឹកចិត្តឱ្យសិស្សខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីសម្រេចទៅតាមគោលដៅ ដោយបង្ហាញការខិតខំប្រឹងប្រែងឈានទៅសម្រេចបាននូវលទ្ធផលសិក្សា ជាជាងផ្តោតតែលើពិន្ទុដែលទទួលបាន។*

## ឧបករណ៍រង្វាយតម្លៃ

*១. ការប្រើប្រាស់តេស្តសរសេរ ៖ ការធ្វើតេស្តដោយសរសេរអាចវាស់វែងចំណេះដឹងរបស់សិស្សទៅតាមស្តង់ដាមួយជាក់លាក់ ដូចជា នៅក្នុងសាលារៀន និងនៅពេលបញ្ចប់ភូមិសិក្សា ដូចជាការប្រឡង កម្រិតសាលារៀន ឬការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ក៏ប៉ុន្តែ ការធ្វើតេស្តដោយសរសេរ*

នេះមានចំណុចខ្សោយ ដោយមិនអាចវាស់វែងចំណេះដឹង និងសមត្ថភាពទូលំទូលាយរបស់សិស្ស។ ការប្រើប្រាស់សំណួរពហុជម្រើសត្រូវផ្ដោតលើបំណិនគិតកម្រិតទាប (ការចងចាំ ការយល់ និងការអនុវត្ត) ចំណែកការប្រើប្រាស់ការតែងសេចក្ដីត្រូវផ្ដោតលើបំណិនគិតកម្រិតខ្ពស់ (ការវិភាគ និងការវាយតម្លៃ)។

២. **ការដាក់កិច្ចការឱ្យធ្វើនៅផ្ទះ ៖** លើកទឹកចិត្តឱ្យសិស្សចេះស្រាវជ្រាវ ចេះគិតដោយបង្កើតថ្មី និងការអនុវត្តនូវចំណេះដឹងរបស់សិស្ស។

៣. **វិធីសាស្ត្រវាយតម្លៃក្រៅពីការធ្វើតេស្ត ៖** ការរៀបចំគម្រោងការធ្វើពិព័រណ៍ ការចូលរួមក្លឹបសិក្សា ការតស៊ូមតិ ការធ្វើបទបង្ហាញជាដើមដែរ។

៤. **ការធ្វើតេស្តតាមបែបបច្ចេកវិទ្យា ៖** ការប្រើបច្ចេកវិទ្យាក្នុងការធ្វើតេស្ត។

## វាយតម្លៃការសិក្សាបែបគម្រោង

ការវាយតម្លៃគម្រោងមានពីរផ្នែកសំខាន់ៗ ៖

១. ការវាយតម្លៃលើការទទួលបានព័ត៌មាននិងប្រមូលទិន្នន័យរបស់សិស្ស ដើម្បីបង្កើតផលិតផលចុងក្រោយ ឬការអនុវត្តរបស់សិស្ស ដោយសួរសំណួរមួយចំនួនដូចខាងក្រោម ៖

- តើសិស្សអាចបង្កើតសំណួរសមស្រប ដើម្បីផ្ដោតលើការស្រាវជ្រាវដែរឬទេ?
- តើគេអាចរកព័ត៌មានថ្មីៗ ដែលទាក់ទងនឹងប្រធានបទរបស់គេដែរឬទេ?
- តើគេមានបានដកស្រង់គំនិតអ្នកជំនាញដែរឬទេ?
- តើគេអាចវែកញែករវាងហេតុការណ៍និងមតិយោបល់ដែរឬទេ?
- តើគេអាចបំប្លែងទិន្នន័យរបស់គេជាតារាង ក្រាហ្វិក ដ្យាក្រាម... ដែរឬទេ?

- *តើគេអាចញែករវាងទិន្នន័យដែលមានស្រាប់និងទិន្នន័យបឋមដែរឬទេ?*
- *តើគេបានប្រើឯកសារយោងរបស់អ្នកនិពន្ធដែលគេបានដកស្រង់ត្រឹមត្រូវដែរឬទេ?*

*២. ការវាយតម្លៃផលិតផលចុងក្រោយ ឬការប្រតិបត្តិរបស់សិស្សនៅពេលដែលគេបង្ហាញនិងធ្វើការបកស្រាយ អ្នកវាយតម្លៃគួរសួរសំណួរមួយចំនួនដូចខាងក្រោម ៖*

- *តើសិស្សអាចបង្កើតឯកសារស្រាវជ្រាវដោយមានភាពទាក់ទាញដែរឬទេ?*
- *តើសិស្សមានទំនុកចិត្តក្នុងការឡើងធ្វើបទបង្ហាញដែរឬទេ?*
- *តើគេអាចបង្ហាញគំនិតរបស់គេនៅក្នុងទម្រង់នៃការជជែកវែកញែកនិងមានការគាំទ្រមតិស្រប មតិផ្ទុយដែរឬទេ?*
- *តើគេមានប្រើទិន្នន័យបឋមនិងទិន្នន័យដែលមានស្រាប់ដើម្បីគាំទ្រការស្រាវជ្រាវរបស់គេបានសមស្របដែរឬទេ?*
- *តើអំណះអំណាងរបស់ពួកគេមានហេតុផលនិងតក្កដែរឬទេ?*
- *តើគេបង្ហាញគំនិតរបស់គេទៅតាមលំដាប់លំដោយដែរឬទេ?*

## ការវាយតម្លៃក្នុងការសិក្សាអក្សរសិល្ប៍

*លំហាត់ ៖ ចូរអានសៀវភៅ* «To Kill a Mockingbird»

- *អ្នកត្រូវសរសេរអត្ថបទវិភាគពីសៀវភៅដែលបានអាន ដែលត្រូវប្រើពាក្យពី៥០០ពាក្យទៅ១០០០ពាក្យ។*
- *១) ត្រូវរក និងពិភាក្សាពីប្រធានបទនៃសៀវភៅ តួអង្គសំខាន់ៗ និងស្ថានភាពនៅក្នុងសៀវភៅ។*
- *២) ផ្សារភ្ជាប់រឿងនៅក្នុងសៀវភៅ ទៅនឹងបទពិសោធផ្ទាល់ខ្លួនរបស់អ្នក។*

## តារាងវាយតម្លៃ

| ឈ្មោះគ្រូ | A គំនិត និង ខ្លឹមសារ | B ការរៀបចំ គំនិត | C របៀបសរសេរ និងភាសា | ពិន្ទុសរុប/30 | កម្មវិធី ពាក់កណ្ដាលឆ្នាំ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

# ៥.៤.ការវាយតម្លៃក្នុងការសិក្សាអក្សរសិល្ប៍

### លក្ខណៈវិនិច្ឆ័យ A

*១. តើសិស្សសរសេរពីប្រធានបទនៅក្នុងសៀវភៅ ដោយប្រើប្រាស់គំនិតផ្ទាល់ខ្លួនបានពេញលេញដែរឬទេ?*

*២. តើសិស្សប្រើប្រាស់នូវគំនិតផ្ទាល់ខ្លួន ដើម្បីពន្យល់ និងភ្ជាប់គំនិតរបស់ខ្លួន ជាមួយប្រធានបទនៅក្នុងសៀវភៅដែរឬទេ?*

*៣. តើសិស្សបានឆ្លើយនឹងសំណួរ ៖ «តើប្រធានបទនេះមានឥទ្ធិពលយ៉ាងដូចម្ដេចលើរូបខ្ញុំដែរឬទេ?» តើចម្លើយបានពេញលេញដែរឬទេ? តើអ្នកចង់ឃើញចម្លើយលម្អិតផ្សេងទៀតដែរឬទេ?*

*តើសិស្សបានប្រើប្រាស់ពាក្យពេចន៍ ដើម្បីលើកជាឧទាហរណ៍ និងពន្យល់ពីសារៈសំខាន់នៅក្នុងសៀវភៅ និងនៅក្នុងជីវិតដែរឬទេ?*

### លក្ខណៈវិនិច្ឆ័យ B

*១. តើអត្ថបទវិភាគរៀបចំសរសេរ ដោយបង្ហាញពីគំនិតចំនួន ១ សសេរនៅក្នុងកថាខណ្ឌមួយដែរឬទេ?*

*២. តើសិស្សសរសេរដោយចេះភ្ជាប់កថាខណ្ឌមួយ ឬគំនិតមួយទៅកថាខណ្ឌឬគំនិតមួយទៀតដែរឬទេ?*

*៣. តើរចនាសម្ព័ន្ធនៃអត្ថបទសំណេរងាយស្រួលក្នុងការអានដែរឬទេ?*

## ៥.៥. ការវាយតម្លៃសិស្ស

*១. តើសិស្សចេះសរសេរក្នុងសេចក្ដីផ្ដើម ដោយប្រើពាក្យពេចន៍ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់អ្នកអានដែរឬទេ?*

*២. នៅក្នុងសេចក្ដីសន្និដ្ឋានផ្នែកខាងក្រោយ តើសិស្សចេះសំយោគគំនិត វាយតម្លៃ និងធ្វើការសន្និដ្ឋានដែរឬទេ?*

*៣. តើសិស្សបានមើលអត្ថបទរបស់ខ្លួនឡើងវិញ ដើម្បីកែអក្ខរាវិរុទ្ធ និងកំហុសវេយ្យាករណ៍ដែរឬទេ?*

*៤. តើសិស្សបានប្រើពាក្យសម្ដីបែបដែរឬទេ?*

*៥. ការផ្ដល់យោបល់ផ្សេងទៀត ដើម្បីជួយសិស្សក្នុងការសរសេរ។*

## ៥.៦.ការវាយតម្លៃក្នុងការសិក្សាអក្សរសិល្ប៍

***វិមលា** រៀនភាសាអង់គ្លេស និងទទួលបានលទ្ធល្អប្រសើរណាស់នៅក្នុងឆមាសនេះ។ គាត់ចេះគ្រាប់តាមអ្នកនិពន្ធ ដែលបង្ហាញឱ្យឃើញថា គាត់អាចកំណត់បានច្បាស់នូវចំណុចសំខាន់ៗនៃរបៀបសរសេររបស់អ្នកនិពន្ធ ហើយប្រើប្រាស់របៀបសរសេរនេះ ដើម្បីស្វែងរកគំនិតពាក់ព័ន្ធនឹងរឿងនិពន្ធ។ យើងត្រូវស្ងើចសរសើរគាត់ ដែលបានធ្វើកិច្ចការនេះបានយ៉ាងល្អឥតខ្ចោះ។*

***វិមលា** បានសរសេរចម្លើយ និងរៀបចំគម្រោងតែងសេចក្ដីបានយ៉ាងជោគជ័យ ដែលបង្ហាញនូវការប្ដេជ្ញាចិត្តរបស់គាត់ ក្នុងការពន្យល់ពីគំនិត ដែលគាត់ពិចារណាបានយ៉ាងល្អ។*

***វិមលា** តែងតែត្រៀមអានសៀវភៅសម្រាប់ពិភាក្សាក្នុងថ្នាក់រៀនជានិច្ច ហើយមតិយោបល់ ដែលគាត់បានលើកឡើងបង្ហាញថាគាត់គិតពីរឿងនេះបានយ៉ាងស៊ីជម្រៅ។*

*នៅពេលចូលរៀនក្នុងមេរៀននៃឆមាសខាងមុខ ដែលផ្ដោតលើការបញ្ចេញមតិយោបល់ និងការវិភាគអក្សរសិល្ប៍ វិមលា ត្រូវផ្ដោតការយកចិត្តទុកដាក់ ដើម្បីក្លាយទៅជាសិស្សឯករាជ្យជាងមុនម្នាក់ ដែលអាចពន្យល់ និង*

*អធិប្បាយនូវគំនិតរបស់គាត់ដែលសរសេរ។ ភាពឯករាជ្យនេះចាំបាច់ណាស់ នៅពេលដែល វិមលា បន្តរៀនថ្នាក់លើទៀត។ម្យ៉ាងទៀត វិមលា ត្រូវពិចារណា ចូលរួមឱ្យបានខ្លាំងក្លាក្នុងការពិភាក្សា ក្នុងថ្នាក់រៀន ដើម្បីជួយរៀបចំគំនិត និងជួយកែលម្អគំនិតរបស់មិត្តរួមថ្នាក់។*

*វិមលា តែងតែអនុវត្តជាប់ជានិច្ច និងបានធ្វើកិច្ចការខាងផ្នែកភាសា អង់គ្លេស និងបង្ហាញពីការតាំងចិត្តយ៉ាងមោះមុត ដើម្បីកែលម្អកម្រិតចំណេះ ដឹងភាសាអង់គ្លេស។*

## ៥.៧. ការវាយតម្លៃក្នុងការរិះរកក្នុងការរៀនវិទ្យាសាស្ត្រ

### ការសិក្សាវិទ្យាសាស្ត្រតាមបែបរិះរក

| កម្រិតសមត្ថភាព | ពិពណ៌នា |
|---|---|
| ០ | សិស្សសម្រេចមិនបានតាមស្តង់ដារដែលពិពណ៌នាខាងក្រោម |
| ១-២ | សិស្សព្យាយាមកំណត់គោលដៅនៃការអង្កេត និងលើកឡើងពីអញ្ញត្រ តែមិនបានពេញលេញ ឬមិនបានសិក្សាពេញលេញ។ វិធីសាស្ត្រដែលសិស្សបានស្នើឡើងមានលក្ខណៈត្រឹមត្រូវតែមួយផ្នែកប៉ុណ្ណោះ។ សិស្សមិនបានវាយតម្លៃពីវិធីសាស្ត្រ ឬ វាយតម្លៃមិនបានពេញលេញ។ |
| ៣-៤ | សិស្សបានកំណត់គោលដៅនៃការអង្កេត និងផ្តល់ការពន្យល់ តែការរៀបចំមិនបានពេញលេញ។ សិស្សបានលើកឡើងពីរូបមន្ត និងអញ្ញត្របានខ្លះ និងបានពិពណ៌នាពីរបៀបសិក្សាស្រាវជ្រាវ។ វិធីសាស្ត្រដែលសិស្សបានស្នើឡើងមានលក្ខណៈពេញលេញ និងរួមបញ្ចូលការប្រើប្រាស់សម្ភារៈ និងឧបករណ៍បានត្រឹមត្រូវ។ សិស្សបានវាយតម្លៃពីវិធីសាស្ត្រ តែការវាយតម្លៃមិនបានពេញលេញ។ |
| ៥-៦ | សិស្សបានកំណត់គោលដៅនៃការអង្កេត និងលើកឡើងពីសម្មតិកម្មដែលអាចធ្វើតេស្តបាន និងផ្តល់ការពន្យល់ ដោយប្រើប្រាស់វិធីសាស្ត្រត្រិះរិះតាមបែបវិទ្យាសាស្ត្រ។ សិស្សបានកំណត់អញ្ញត្រសមស្រប និងបានពន្យល់ពីរបៀបប្រើប្រាស់បញ្ញត្តិនេះ។ សិស្សបានវាយតម្លៃពីវិធីសាស្ត្រ និងបានផ្តល់យោបល់លើភាពទុកចិត្តនៃវិធីសាស្ត្រ។ សិស្សបានស្នើពីវិធីក្នុងការកែលម្អ និងផ្តល់យោបល់ ដើម្បីធ្វើការត្រិះរិះបន្ថែមទៀត បើចាំបាច់។ |
| ការវាយតម្លៃរបស់គ្រូ | មូលវិចារ ៖ធ្វើបានល្អណាស់ វិមលា ! ធ្វើការសិក្សាបានហ្មត់ចត់។ សូមបន្តដូចនេះទៀត។ កម្រិតសមត្ថភាព ៖ ៦ |

# ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge : La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- *ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩*

៨- Public Finance in Cambodia, 2009

៩- *ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩*

១០- *ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩*

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- *ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣*

១៥- *សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥*

១៦- *កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦*

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍ ឆ្នាំ១៩៨០) - ឆ្នាំ២០១៧
១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧
១៩- Series of Lectures in Public International Law, 2018
២០- សិក្សាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨
២១- Droit International Économique, 2018
២២- Education Reform in Cambodia, 2018
២៣- វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា - ឆ្នាំ២០១៩
២៤- ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក - ឆ្នាំ ២០១៩
២៥- កំណាព្យអប់រំ ៖ សម្រាប់ទិវាគ្រូបង្រៀន ៥តុលា -ឆ្នាំ២០១៩
២៦- 31 Lectures on The International Law of the Sea 2019
២៧- អក្សរសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ និងសម័យអង្គរ តាមរយៈសិលាចារឹក-ឆ្នាំ២០២០
២៨- កំណាព្យអប់រំ ៖ អារ្យធម៌ខ្មែរ -ឆ្នាំ២០២០
២៩-កំណែទម្រង់សាលារៀននៅកម្ពុជា - ឆ្នាំ២០២០
៣០- ជំនួយស្មារតីសម្រាប់សិស្សថ្នាក់ទី១២ - គណិតវិទ្យា-ឆ្នាំ២០២០
៣១- ទស្សនវិជ្ជា និងទ្រឹស្តីស្តីពីការអប់រំ - ឆ្នាំ២០២១
៣២- អក្សរសិល្ប៍ និងភាសាខ្មែរកណ្តាល តាមរយៈសិលាចារឹកនគរវត្ត -ឆ្នាំ២០២១
៣៣- បាឋកថាទិវាគ្រូបង្រៀន បរិវត្តកម្មឌីជីថលនៃការអប់រំ បំណិនសតវត្សរ៍ទី២១ និងកំណែទម្រង់វិធីសាស្ត្របង្រៀន-ឆ្នាំ២០២១
៣៤- បាឋកថាទិវាជាតិអំណាន ការអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍ

កុមារ -២០២២

៣៥-ឈ្វេងយល់អំពីអាស៊ាន តួនាទីច្បាប់ និងវិស័យអប់រំក្នុងសមាហរណកម្មអាស៊ាន ២០២២